**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តសន្តិកម្មនៅកម្ពុជា ៖ ករណីការចុះបញ្ជីផ្ទេរអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **គា សៀវឡាយ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២២ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **គា សៀវឡាយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២២ (ថ្នាក់អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមធ្វើការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក និង អ្នកម្តាយជាទីគោរព
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យ
- លោកបណ្ឌិត **ហាប់ ផល្លី** ជាសាស្រ្តាចារ្យណែនាំ
- លោកគ្រូ អ្នកគ្រូដែលទទួលបន្ទុកថ្នាក់ និងទទួលបន្ទុកផ្នែកកិច្ចការស្រាវជ្រាវ
- សាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកឪពុក អ្នកម្តាយជាអ្នកមានគុណដែលបានផ្តល់កំណើតដល់កូន ព្រមទាំងបានចិញ្ចឹមបីបាច់មើលថែទាំអប់រំ ទូន្មានប្រៀនប្រដៅ និងផ្គត់ផ្គង់កូនគ្រប់បែបយ៉ាង រហូតដល់កូនបានរៀនចប់ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដោយពុំមានការខ្វះខាតអ្វីឡើយ។

ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង លោក លោកស្រីសាស្រ្តាចារ្យ គណៈគ្រប់គ្រង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំយកចិត្តទុកដាក់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីបណ្តុះបណ្តាលដល់រូបខ្ញុំ និងនិស្សិតដទៃទៀត។

ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណចំពោះសាស្រាចារ្យណែនាំ បណ្ឌិត **ហាប់ ផល្លី** ដែលបានណែនាំ បង្ហាត់បង្រៀន និងបណ្តុះបណ្តាលនូវចំណេះដឹងទាក់ទងនឹងសារណានេះយ៉ាងយកចិត្តទុកដាក់លើរូបខ្ញុំ ហើយថែមទាំងបានជួយកែតម្រូវនូវកំហុសឆ្គងនានា។ ជាចុងក្រោយ ខ្ញុំសូមជូនពរឱ្យអ្នកមានគុណទាំងអស់ឱ្យជួបតែសំណាងល្អ និងមានសុខភាពមាំមួន ដើម្បីជាម្លប់ដល់កូនចៅជំនាន់ក្រោយ ហើយអាចបំពេញភារកិច្ចរបស់ខ្លួនបន្តទៀត។ ដោយការគោរព និងការដឹងគុណយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ។

# អារម្ភកថា

នៅក្នុងឆ្នាំទី ៤ នៃការសិក្សាបរិញ្ញាបត្រនីតិសាស្រ្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ខ្ញុំបាទបានចងក្រង និងតាក់តែងសារណាបញ្ចប់ការសិក្សា ដោយលើកឡើងនូវប្រធានបទ "**ការអនុវត្តសន្តតិកម្មនៅកម្ពុជា៖ ករណីការចុះបញ្ជីផ្ទេរអចលនវត្ថុ**" មកធ្វើការបកស្រាយ។ ការលើកយកប្រធានបទនេះមកធ្វើការបកស្រាយ ក្នុងគោលបំណងពង្រីកចំណេះដឹងផ្នែកនេះបន្ថែមទៀត ព្រោះនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ប្រជាពលរដ្ឋពុំទាន់បានយល់ដឹងច្បាស់អំពីការអនុវត្តសន្តតិកម្ម ហើយបញ្ហាឈ្លោះប្រកែកគ្នាក្នុងគ្រួសារអំពីការបែងចែកមត៌ក ក៏នៅតែមាននៅឡើយ។

ប្រធានបទនេះ នឹងចូលរួមចំណែកក្នុងការពង្រឹង និងអភិវឌ្ឍចំណេះដឹងលើផ្នែកសន្តតិកម្មនៅកម្ពុជា ដោយបានលើកឡើងអំពីសញ្ញាណ ការអនុវត្ត នីតិវិធី បញ្ហាប្រឈម និងដំណោះស្រាយដែលទាក់ទងនឹងសន្តតិកម្មជាដើម។ ប្រធានបទនេះ មានបំណងចូលរួមជាចំណេះដឹង និងគំនិតខ្លះៗដល់និស្សិតដែលសិក្សាផ្នែកច្បាប់ និងផ្នែកផ្សេងៗទៀត រួមជាមួយនឹងប្រជាពលរដ្ឋទូទៅ ដែលមានបំណងចង់ស្វែងយល់បន្ថែមអំពីសន្តតិកម្ម។ បន្ទាប់ពីប្រជាពលរដ្ឋបានយល់ដឹងច្បាស់អំពីសន្តតិកម្ម សង្គមនឹងកាត់បន្ថយនូវវិវាទទាក់ទងនឹងការដណ្ដើមមត៌ក នោះពួកគាត់ប្រាកដជារស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរម្យនា ។

ទោះបីជាមានចំណុចលំបាកខ្លះៗទាក់ទងនឹងសារណានេះ ក៏ខ្ញុំមិនបានបោះបង់ចោលឡើយ ប៉ុន្តែបែរជាជំរុញលើកទឹកចិត្តឱ្យខ្ញុំបាទខិតខំអស់ពីសមត្ថភាព ក្នុងការស្រាវជ្រាវ និងរៀបចំសារណានេះ។ ខ្ញុំគិតថា បន្ទាប់ពីបញ្ចប់សារណានេះទៅ ខ្ញុំកាន់តែមានចំណេះដឹងបន្ថែមទៀតទាក់ទងនឹងបច្ចុប្បភាពនៃសន្តតិកម្មនៅកម្ពុជា។

# មាតិកា


........................................................................................................................................ ទំព័រ

**សេចក្តីផ្តើម** ........................................................................................... ១

**ជំពូកទី១ សញ្ញាណទូទៅនៃសន្តតិកម្ម** ........................................................ ៤

**១.១. ប្រវត្តិនៃសន្តតិកម្ម** ........................................................................ ៤

**១.២. ការវិវត្តនៃសន្តតិកម្ម** ..................................................................... ៦

**ជំពូកទី២ ការចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម** ......................... ៨

**២.១. សន្តតិកម្មមានមតកសាសន៍** ............................................................ ៨

២.១.១. ការអនុវត្តតាមបណ្តាំមតិក ................................................................ ៩

២.១.១.១. វិធីនៃការប្រតិបត្តិសន្តតិកម្មមានបណ្តាំមតិក ..................................... ៩

ក. បណ្តាំមតិកត្រឹមត្រូវតាមទម្រង់ ............................................................ ៩

ខ. បណ្តាំមតិកដែលមិនត្រឹមត្រូវតាមទម្រង់ ................................................. ១០

២.១.១.២. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ ..................................................... ១១

ក. សកម្មភាពរបស់អ្នកស្នើសុំចុះបញ្ជី ........................................................ ១១

ខ. សកម្មភាពរបស់មន្ត្រីចុះបញ្ជី ............................................................... ១៣

២.១.២. ការមិនអនុវត្តតាមបណ្តាំមតិក .......................................................... ១៥

២.១.២.១. ការដោះស្រាយក្រៅប្រព័ន្ធតុលាការ .................................................. ១៦

២.១.២.២. ការដាក់ពាក្យសុំទៅតុលាការ ......................................................... ១៧

២.១.២.៣. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ ..................................................... 20

**២.២. សន្តតិកម្មគ្មានមតកសាសន៍** ........................................................... 20

២.២.១. ការបែងចែកដោយការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់ ........................ 20

២.២.១.១. ការធ្វើឯកសារសម្រាប់ចុះបញ្ជីផ្ទេរអចលនវត្ថុ ......................................... 21

២.២.១.២. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ ..................................................... 21

២.២.២. ការបែងចែកដោយតុលាការ ....................................................................21
២.២.២.១. មូលហេតុនៃការដាក់ពាក្យសុំ.........................................................................២១
២.២.២.២. ការរៀបចំពាក្យសុំ និងភស្តុតាងបញ្ជាក់សម្រាប់តុលាការពិនិត្យ.........២២
២.២.២.៣. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុបន្ទាប់ពីមានសេចក្តីសម្រេចរបស់តុលាការ............................................................................................................ ២៣
**ជំពូកទី៣ បញ្ហាប្រឈម**............................................................................................២៥
**៣.១. អចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី**..................................................................២៥
៣.១.១. មូលហេតុនៃការមិនទៅចុះបញ្ជីបន្ទាប់ពីទទួលបានមតិក.........................២៥
៣.១.១.១. ចំណេះដឹង និងផ្នត់គំនិតរបស់ប្រជាពលរដ្ឋ .....................................២៥
៣.១.១.២. ភាពមិនច្បាស់លាស់នៃយន្តការរបស់រដ្ឋ .........................................២៦
៣.១.២. ផលវិបាកនៃការចុះបញ្ជីអចលនវត្ថុបន្ទាប់ពីទទួលបានដោយសន្តតិកម្ម....២៦
៣.១.៣. អានុភាពនៃកិច្ចសន្យា..................................................................................២៨
៣.១.៤. ដំណោះស្រាយ ............................................................................................២៨
៣.១.៤.១. ការចុះបញ្ជីអចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី..............................២៨
៣.១.៤.២. ការយកចិត្តទុកដាក់ពីរដ្ឋ ..................................................................៣០
**៣.២. អចលនវត្ថុបានចុះបញ្ជីរួច** ......................................................................................30
៣.២.១. មូលហេតុ.......................................................................................................៣១
៣.២.២. បញ្ហាដែលអាចកើតមាន ..................................................................................៣១
៣.២.៣. ដំណោះស្រាយ ..............................................................................................៣១
៣.២.៣.១. ការចុះបញ្ជីអចលនវត្ថុ.......................................................................៣១
៣.២.៣.២. ការយកចិត្តទុកដាក់ពីរដ្ឋ ................................................................... ៣២
**សេចក្តីសន្និដ្ឋាន**..........................................................................................................៣៣
**អនុសាសន៍**....................................................................................................................៣៥
**ឯកសារយោង**

# ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ធ្លាប់បានខ្ទេចខ្ទាំដោយសារតែសង្គ្រាម ជាពិសេសនៅរបបប៉ុលពត ដែលធ្វើឱ្យកម្ពុជាបាត់បង់ស្ទើរតែទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងកម្រងច្បាប់នានា ហើយចាប់ផ្តើមពីចំណុចសូន្យមកវិញ។ ដើម្បីកសាងប្រទេសជាតិឱ្យមានភាពរឹងមាំ និងលើកកម្ពស់សេដ្ឋកិច្ចឱ្យមានការអភិវឌ្ឍ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើគ្រប់វិស័យ ជាពិសេសវិស័យច្បាប់។ ការកសាងមូលដ្ឋានច្បាប់មានភាពចាំបាច់ក្នុងការផ្តល់នូវសុវត្ថិភាពគតិយុត្តជូនប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់មានទំនុកចិត្ត ក្នុងការប្រកបរបរចិញ្ចឹមជីវិតដោយគ្មានការព្រួយបារម្ភពីការបាត់បង់ផលរបរដែលខ្លួនរកបាន ព្រមទាំងទាក់ទាញអ្នកវិនិយោគឱ្យមកវិនិយោគនៅកម្ពុជាកាន់តែច្រើនឡើង។ ក្នុងនោះផងដែរ កម្មសិទ្ធិឯកជននេះ ត្រូវបានគេទទួលស្គាល់តាមរយៈ រដ្ឋធម្មនុញ្ញកម្ពុជាដែលបានបញ្ញត្តពីការទទួលស្គាល់នូវកម្មសិទ្ធិឯកជន[1] ក្នុងគោលបំណងការពារសិទ្ធិជាម្ចាស់នៃទ្រព្យសម្បត្តិដែលបុគ្គលទាំងនោះខិតខំរកទាំងលំបាក។ ជាទូទៅ បុគ្គលម្នាក់ៗកើតមក ត្រូវប្រកបរបរចិញ្ចឹមជីវិតដើម្បីផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ។ បន្ទាប់ពីខិតខំប្រឹងប្រែងយ៉ាងលំបាកក្នុងការស្វែងទ្រព្យសម្បត្តិ បុគ្គលទាំងនោះអាចសល់ទ្រព្យសម្បត្តិខ្លះ ទោះតិចក្តី ឬច្រើនក្តីដល់កូនចៅជំនាន់ក្រោយ។ ដូចនេះ អត្ថិភាពនៃកម្មសិទ្ធិឯកជន ធ្វើឱ្យប្រជាពលរដ្ឋមានទឹកចិត្តប្រកបរបររបស់ខ្លួនអស់ពីសមត្ថភាព ព្រោះប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួនពេលនៅរស់ហើយពេលស្លាប់ទៅ ទ្រព្យនោះមិនត្រូវធ្លាក់ទៅលើអ្នកណាផ្សេងឡើយក្រៅពីញាតិសន្តាន ឬបុគ្គលដែលមតកជនមានបំណងប្រគល់ឱ្យ។ យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បុគ្គលដែលបានទទួលមរណភាពនោះ ហៅថា "មតកជន" ចំណែកបុគ្គលដែលបានស្នងមរតកនោះ ហៅថា "សន្តតិកម្ម"។ គួរបញ្ជាក់ផងដែរថា ទ្រព្យដែលបានបន្សល់ទុកនោះអាចជា ទ្រព្យសកម្ម ឬទ្រព្យអកម្ម។ ពេលនៅមានជីវិត មតកជនអាចបង្ហាញឆន្ទៈ ក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ខ្លួនបានតាមរយៈលិខិតបណ្តាំ។ ទោះបីជាមតកជន មិនបានបង្ហាញឆន្ទៈពេលនៅមានជីវិតក៏ដោយ ទ្រព្យនោះនៅតែធ្លាក់ជាកម្មសិទ្ធិរបស់សន្តតិជនរបស់ជននោះដដែល តាមរយៈការព្រមព្រៀងគ្នារបស់សន្តតិជនទាំងអស់។ ទោះបីជាមានបណ្តាំ ឬគ្មានបណ្តាំក៏ដោយ វិវាទរវាងសហសន្តតិជនអាចកើតមានឡើង ជាពិសេសនៅក្នុងគ្រួសារធំដែលត្រូវបានបន្សល់ទុកទ្រព្យសម្បត្តិច្រើន ដោយសារតែអាចនឹងមានស្ថានភាពដែលសន្តតិជនម្នាក់ៗ ចង់បានទ្រព្យច្រើនរៀងៗខ្លួន។ វត្តមាននៃក្រមរដ្ឋប្បវេណី ជាការចាំបាច់ក្នុងការចូលអន្តរាគមន៍ក្នុងវិស័យនេះ សម្រាប់ជាយន្តការក្នុងការដោះស្រាយ ក៏ដូចជាកាត់

[1] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា, មាត្រា ៥០ កថាខណ្ឌ២ បញ្ញត្តថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន។

បន្តយជម្លោះ មានន័យថា ទោះបីជាមាន ឬគ្មានបណ្តាំក៏ដោយ ប្រសិនបើពុំមានការឯកភាពគ្នាលើការបែងចែកទ្រព្យទេ សហសន្តតិជនអាចដាក់ពាក្យទៅតុលាការ ដើម្បីឱ្យតុលាការដោះស្រាយផ្អែកតាមមូលដ្ឋានច្បាប់ជាធរមាន។

ការផ្ទេរទ្រព្យសម្បត្តិដែលជាចលនវត្ថុ ពុំឆ្លងកាត់នីតិវិធីស្មុគស្មាញឡើយ ព្រោះការផ្ទេរសិទ្ធិកម្មសិទ្ធិលើចលនវត្ថុ អាចស្តែងឡើងតាមរយៈការកាន់កាប់ផ្ទាល់របស់សន្តតិជន។ ដោយឡែកចំពោះអចលវត្ថុវិញ ការកាន់កាប់របស់សន្តតិជនពុំទាន់បង្កើតអានុភាពជាម្ចាស់សិទ្ធិគ្រប់គ្រាន់ដើម្បីតតាំងជាមួយតតិយជនឡើយ ពោលគឺទាមទារឱ្យមានការចុះបញ្ជីអចលនវត្ថុជាមុនសិន។ ការចុះបញ្ជីពិតជាសំខាន់ណាស់ ដែលមិនត្រឹមតែផ្តល់សិទ្ធិក្នុងប្រើប្រាស់ កាន់កាប់ និងចាត់ចែងអចលនវត្ថុនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរក្សាសុវត្ថិភាពគតិយុត្តជូនសន្តតិជនឱ្យជៀសវាងពីវិវាទលើអចលនវត្ថុនោះទៀតផង។

វត្តមាននៃកម្មសិទ្ធិឯកជន បានបង្កើតឱ្យមានសន្តតិកម្ម។ តើអ្វីទៅជាសន្តតិកម្ម? តើសន្តតិកម្មអាចប្រព្រឹត្តទៅបានតាមវិធីណាខ្លះ? បន្ទាប់ពីទទួលមតិកជាអចលនវត្ថុ តើសន្តតិជនត្រូវធ្វើដូចម្តេចដើម្បីក្លាយជាម្ចាស់ពិតប្រាកដលើអចលនវត្ថុនោះ? ប្រធានបទអំពី "ការអនុវត្តសន្តតិកម្មនៅកម្ពុជា៖ ករណីការចុះបញ្ជីផ្ទេរអចលនវត្ថុ" ដែលបានរៀបរាប់ត្រួសៗខាងលើ នឹងត្រូវបកស្រាយក្នុងអត្ថបទខាងក្រោម។

ក្នុងការស្រាវជ្រាវលើប្រធានបទខាងលើនេះ ខ្ញុំបាទមានគោលបំណងធ្វើការពន្យល់វែកញែកលើការអនុវត្តការចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្មនៅកម្ពុជា រួមជាមួយនឹងបញ្ហាដែលកើតមានឡើង និងដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនោះ។

យ៉ាងណាមិញ សារណានេះ ស្រាវជ្រាវនូវចំណុចមួយចំនួននៃសន្តតិកម្ម ជាពិសេសការចែងនៃច្បាប់ និងការអនុវត្តជាក់ស្តែងទាក់ទងនឹងដំណើរការនៃការចុះបញ្ជីផ្ទេរអចលនវត្ថុតាមរយៈសន្តតិកម្មនៅកម្ពុជា រួមជាមួយបញ្ហាមួយចំនួនដែលបានកើតមានឡើងនាពេលបច្ចុប្បន្ន និងផ្តល់ជូននូវដំណោះស្រាយខ្លះៗដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានកើតមានទាំងនេះ។ នៅពេលដែលសារណានេះដាក់ចេញទៅ សង្ឃឹមថា នឹងអាចចូលរួមជាចំណែកមួយសម្រាប់ផ្តល់ជាចំណេះដឹងដល់អ្នកសិក្សាជំនាន់ក្រោយ អភិវឌ្ឍក្នុងវិស័យច្បាប់ និងឆ្លើយតបទៅបញ្ហាដែលកំពុងកើតមានក្នុងសង្គមនាពេលបច្ចុប្បន្ន។

ការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើនេះ ផ្អែកទៅលើក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាមូលដ្ឋានចម្បង និងឯកសារច្បាប់ផ្សេងៗទៀតទាក់ទងនឹងសន្តតិកម្មនៅកម្ពុជា។ ក្រៅពីផ្អែកលើឯកសារច្បាប់មួយចំនួន ខ្ញុំបាទបានប្រើប្រាស់ចំណេះដឹងដែលទទួលបានពីសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យពីមុនៗផងដែរ។ ការស្រាវជ្រាវលើប្រធានបទនេះ ជាការរៀបរៀងនូវខ្លឹមសារនៃច្បាប់នានាដែលពាក់ព័ន្ធ និងធ្វើការវិភាគលើចំណុចខ្លះៗ។

សារណានេះចែកចេញជាបីជំពូកធំៗ។ ជំពូកទី ១ រៀបរាប់អំពីសញ្ញាណទូទៅសន្តតិកម្ម ដោយ ផ្តោតសំខាន់ទៅលើប្រវត្តិនៃសន្តតិកម្ម និងការវិវត្តនៃសន្តតិកម្ម។ ចំណែកឯជំពូកទី ២ បកស្រាយអំពីការចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម ទាំងករណីសន្តតិកម្មមានមតកសាសន៍ និងសន្តតិកម្មគ្មានមតកសាសន៍។ រីឯជំពូកទី ៣ ពិភាក្សាអំពីបញ្ហាប្រឈមដែលកើតមានឡើងកន្លងមក ទាំងអចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី និងអចលនត្ថុដែលធ្លាប់បានចុះបញ្ជីរួច តែសន្តតិជនបន្តបន្ទាប់មិនបានយកទៅចុះបញ្ជីបន្ត។

# ជំពូកទី១ សញ្ញាណទូទៅនៃសន្តតិកម្ម

ដើម្បីឈានទៅដល់ការបកស្រាយអំពីប្រធានបទឱ្យបានក្បោះក្បាយ គួរគប្បីស្វែងយល់អំពីសញ្ញាណទូទៅនៃសន្តតិកម្មជាមុនសិន។ ជំពូកទី១នេះ នឹងលើកបង្ហាញអំពីសញ្ញាណទូទៅនៃសន្តតិកម្ម ដែលត្រូវបានបែងចែកជាពីរចំណុចសំខាន់ គឺប្រវត្តិនៃសន្តតិកម្ម និងការវិវត្តនៃសន្តតិកម្ម។

## ១.១. ប្រវត្តិនៃសន្តតិកម្ម

នៅកម្ពុជា របបសន្តតិកម្ម ត្រូវបានចាប់កំណើតតាំងពីសម័យហ្វូណនមកម្ល៉េះ។[2] ការអនុវត្តសន្តតិកម្មនៅសម័យនោះ ភាគច្រើនធ្វើតាមប្រពៃណីតៗគ្នា ដោយពុំទាន់មានវត្តមាននៃច្បាប់ដែលកំណត់អំពីរបបសន្តតិកម្មនៅឡើយ។ គួរកត់សម្គាល់ផងដែរថា នៅសម័យកាលនោះ មិនទាន់មានទំនៀមទំលាប់ក្នុងការបែងចែកទ្រព្យសម្បត្តិទៅឱ្យសហព័ទ្ធឡើយ គឺភាគច្រើនឃើញតែការបែងចែកទ្រព្យសម្បត្តិទៅឱ្យទាយាទ[3]របស់មតកជន។ ដោយសារតែពុំទាន់មានវត្តមាននៃច្បាប់ ពេលខ្លះមតកជនប្រគល់មត៌កទៅឱ្យសន្តតិជនតែម្នាក់ ឯសន្តតិជនផ្សេងទៀតពុំទទួលបានអ្វីសោះ ទាំងដែលខ្លួនមិនបានប្រព្រឹត្តកំហុស។ ការអនុវត្តជាលក្ខណៈប្រពៃណីបែបនេះ ងាយបង្កជាបញ្ហាណាស់ ព្រោះបានបង្កើតនូវភាពអយុត្តិធម៌ចំពោះទាយាទក្នុងវង្សត្រកូល ដែលមិនទទួលបានអ្វីសោះពីបុព្វញាតិរបស់ខ្លួន។ នេះក៏អាចជាមូលហេតុនៃទំនាស់ទាស់ទែងគ្នា ហើយឈានដល់ ការបែកបាក់គ្រួសារ និងសង្គមផងដែរ។

រហូតមកដល់ឆ្នាំ ១៩២០ កម្ពុជាបានបង្កើតក្រមរដ្ឋប្បវេណីដំបូងបំផុតមួយ ដែលស្ថិតក្នុងឥទ្ធិពលនៃក្រមរដ្ឋប្បវេណីបារាំង តទៅហៅថាក្រមរដ្ឋប្បវេណីចាស់[4]។ ក្រមនេះ បានកំណត់អំពីលំដាប់សន្តតិកម្ម ចំណែកមត៌ក និងដំណោះស្រាយចំពោះបញ្ហាផ្សេងៗទាក់ទងនឹងសន្តតិកម្ម។ សញ្ញាណនៃសន្តិកម្មតាមក្រមរដ្ឋប្បវេណីចាស់នេះ ត្រូវបានយកមកអនុវត្ត រហូតដល់ឆ្នាំ ១៩៩២ ទើបលេចចេញនៃសញ្ញាណដដែលនេះនៅក្នុងច្បាប់មួយទៀតដែលមានឈ្មោះថា "ច្បាប់ភូមិបាលឆ្នាំ ១៩៩២"[5]។ សទ្ធានុក្រមនៃច្បាប់នេះ បានឱ្យនិយមន័យសន្តតិកម្ម "ជាការផ្ទេរនូវបេតិកភណ្ឌនៃ

---

[2] មជ្ឈមណ្ឌលឯកសារកម្ពុជា, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៥), ទំព័រ១៥។

[3] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត, *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២* (ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨), ទាយាត គឺបុត្រ បុត្រី អ្នកដែលទទួលទ្រព្យសម្បត្តិ និងមត៌ក, អ្នកដែលត្រូវបន្តវង្សត្រកូល។

[4] ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០។

[5] ច្បាប់ភូមិបាល, លេខ ១០០ក្រ, ១៣ តុលា ១៩៩២, ចាប់ពីមាត្រា ១៧០ ដល់ ១៧៦។

បុគ្គលណាម្នាក់ដែលស្លាប់ឱ្យទៅជនម្នាក់ទៀត ឬច្រើននាក់ដែលហៅថាទាយាទ ឬសន្តតិជន"[6]។ ច្បាប់ភូមិបាលឆ្នាំ ១៩៩២ បានបញ្ញត្តត្រឹមចំណុចខ្លះៗទាក់ទងសន្តតិកម្ម គឺការចាប់ផ្តើមធ្វើសន្តតិកម្ម និងលក្ខណៈសម្បត្តិជាសន្តតិជន។ បន្តមកទៀត ច្បាប់ភូមិបាលឆ្នាំ ២០០១[7] បានចែងអំពីលទ្ធកម្មដោយសន្តតិកម្ម។ តាមការវិភាគបែបកត្តវិទ្យា ច្បាប់ភូមិបាលនេះហាក់បីដូចជាមានឧបនិស្ស័យអនុវត្តតែចំពោះអចលនវត្ថុប៉ុណ្ណោះ ដោយសារតែវិធាននេះ ជាវិធានដោយឡែកនៃអចលនវត្ថុ។ ចំណែកឯសន្តតិកម្មពាក់ព័ន្ធនឹងចលនវត្ថុ និងសិទ្ធិផ្សេងទៀត គឺមិនទាន់មានចែងនៅឡើយ ។

ការវិវត្តនៃច្បាប់ខ្មែរ បានបំពេញចំណុចខ្វះខាតនៃច្បាប់ដែលមានស្រាប់។ នៅឆ្នាំ ២០០៧ ក្រោមកិច្ចសហប្រតិបត្តិការជាមួយជប៉ុន កម្ពុជាមានក្រមរដ្ឋប្បវេណីថ្មីមួយ ដែលបានចែងក្បោះក្បាយអំពីសន្តតិកម្ម តទៅហៅក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ ពាក់ព័ន្ធនឹងបញ្ហាសន្តតិកម្ម ក្រមនេះបានចែងច្បាស់ និងលម្អិតជាងច្បាប់មុនៗ ដោយបានប្រើប្រាស់គន្លឹះទី៨ ទាំងមូលដើម្បីចារឹកតែម្តង។ យោងតាមសទ្ធានុក្រមនៃក្រមរដ្ឋប្បវេណីថ្មីនេះ សន្តតិកម្ម "ជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់"[8]។ របបសន្តតិកម្ម ត្រូវបានចាប់ផ្តើមឡើងដោយមូលហេតុនៃមរណភាព[9] ឬការទទួលការប្រកាសអំពីការបាត់ខ្លួន[10] របស់មតកជន។ នេះមានន័យថា សន្តតិកម្មមិនអាចចាប់ផ្តើមបាននោះទេ ប្រសិនបើមតកជននៅមានជីវិតរស់នៅនៅឡើយ ទោះបីជាមតកជននោះបានធ្វើបណ្តាំរួចរាល់ហើយក៏ដោយ។ យ៉ាងណាមិញ ដើម្បីសម្រួលក្នុងករណីមតកជនបានបាត់ខ្លួន សន្តតិកម្មអាចចាប់ផ្តើមបាន នៅពេលដែលមានសាលក្រមស្ថាពររបស់តុលាការ ដែលបានបញ្ជាក់អំពីការប្រកាសការបាត់ខ្លួនរបស់មតកជននោះ។

អនុលោមតាមច្បាប់ដដែលនេះ សន្តតិកម្មអាចដើរតាមយន្តការពីរយ៉ាងគឺ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។[11] សន្តតិកម្មតាមច្បាប់ (ឬសន្តតិកម្មឥតបណ្តាំ) ជាសន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ក្នុងការបែងចែកទ្រព្យដែលនៅសេសសល់របស់អ្នកស្លាប់ ទៅឱ្យ

[6] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៩, ៣០ សីហា ២០០១, មាត្រា ១៧០ កថាខណ្ឌ ១។
[7] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៩, ៣០ សីហា ២០០១, មាត្រា ៧១ ដល់ ៧៩។
[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ធានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ២១។
[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៥, កថាខណ្ឌ បានចែងថា សន្តតិកម្មត្រូវចាប់ ផ្តើមដោយមរណភាពរបស់មតកជន។
[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣ បានចាត់ទុកជនដែលទទួលការប្រកាសអំពី ការបាត់ខ្លួនថា ជននោះបានទទួលមរណភាព ដូច្នេះហើយសន្តតិកម្មត្រូវបានចាប់ផ្តើម។
[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៥។

ទាយាទ ឬអ្នកស្នងមតិករបស់អ្នកស្លាប់នោះ ដោយហេតុថា ជននោះពុំបានបង្ហាញឆន្ទៈលើការបែងចែកទ្រព្យរបស់ខ្លួនមុនពេលទទួលមរណភាព។ គួរបញ្ជាក់ផងដែរថា របបសន្តតិកម្មតាមច្បាប់នេះ អាចយកមកអនុវត្តបានតែក្នុងករណីដែលសន្តតិជនរបស់អ្នកស្លាប់ ពុំមានការព្រមព្រៀងគ្នាក្នុងការបែងចែកមតិកតែប៉ុណ្ណោះ។ ដោយឡែក សន្តតិកម្មមានបណ្ដាំ ជាសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជនក្នុងការបែងចែកមតិករបស់ខ្លួនទៅឱ្យសន្តតិជន ឬតតិយជន។ សន្តតិកម្មប្រភេទនេះ អាចហៅម៉្យាងទៀតបានថា សន្តតិកម្មតាមមតកសាសន៍។ មតកសាសន៍ សម្ដៅទៅលើ"លិខិតបណ្ដាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្ដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព"[12]។ ដូចនេះ សន្តតិកម្មតាមមតកសាសន៍ ជាបណ្ដាំរបស់មតកជនដែលមានការចាត់ចែងទុកជាមុន។

## ១.២. ការវិវត្តនៃសន្តតិកម្ម

នៅលើពិភពលោក របបសន្តតិកម្ម មានគោលការណ៍ពីរសំខាន់ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទាំងពីរនេះ មានលក្ខណៈខុសដាច់ពីគ្នា។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ជាគោលការណ៍មួយដែលតម្រូវឱ្យសន្តតិជនទទួលយកទាំងស្រុង[13]នូវសិទ្ធិ និងករណីយកិច្ច ពោលគឺទាំងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់មតកជន។ គោលការណ៍នេះមានគុណសម្បត្តិច្រើន ដូចជាចំណេញពេលវេលា និងថវិកា ក្នុងការបែងចែកមតិកដល់សន្តតិជនម្នាក់ៗ។ មួយវិញទៀត គោលការណ៍នេះក៏បានអនុញ្ញាតឱ្យសន្តតិជនធ្វើការសម្រេចចិត្តថា បោះបង់សន្តតិកម្ម[14] ឬទទួលយកដោយមានកម្រិត[15]។ ការកម្រិតបែបនេះ មានគោលបំណងការពារផលប្រយោជន៍របស់សន្តតិជន ជៀសវាងខូចប្រយោជន៍ធ្ងន់ធ្ងរ ក្នុងករណីមតកជនបានបន្សល់ទុកទ្រព្យអកម្មច្រើនជាងទ្រព្យសកម្ម។ បន្ថែមពីនេះ ក៏មានស្ថានភាពមួយចំនួនដែលច្បាប់ទាមទារឱ្យមានមធ្យោបាយសម្រួលចំណែកមតិកលើសហសន្តតិជន ឬជនដែលទទួលបានផលប្រយោជន៍ពិសេស ដូចជាប្រទានកម្មជាអាទិ៍ នៅពេលដែលមតកជននៅមានជីវិត។[16]

---

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី១៧។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៤ បានបញ្ញត្តិថា បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ។

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦០ បានបញ្ញត្តិថា បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះទៅតុលាការ។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៥៨ បានបញ្ញត្តិថា សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិរបស់ខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៣។

ដោយឡែក គោលការណ៍ជម្រះបញ្ជីវិញ គឺជាគោលការណ៍ដែលតម្រូវឱ្យមានការជម្រះសិទ្ធិ និងកាតព្វកិច្ចរបស់មតកជនជាមុនសិន ហើយសន្តតិជនអាចស្នងមត៌កបានតែក្នុងករណីនៅសល់ទ្រព្យសកម្មប៉ុណ្ណោះ។ ប្រសិនករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរខ្លាំងពេក សន្តតិជនត្រូវធ្វើការប្រកាសក្ស័យធននៃមត៌កទាំងអស់នោះ ដើម្បីកុំឱ្យខ្លួនទទួលបន្ទុកលើកាតព្វកិច្ចនោះជំនួសមតកជន។ គោលការណ៍នេះ ហាក់បីដូចជាបង្ហាញអំពីសមភាពរបស់មតកជន និងសន្តតិជន ប៉ុន្តែត្រូវចំណាយពេលវេលា និងថវិការច្រើន ហើយនីតិវិធីនៃការអនុវត្តក៏មានលក្ខណៈស្មុគស្មាញទៀត។

គួរបញ្ជាក់ផងដែរថា ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា បានប្រកាន់យករបបសន្តតិកម្មដោយជម្រះបញ្ជីជាមុន។ ចំណែកឯក្រមរដ្ឋប្បវេណីថ្មីវិញ បានប្រកាន់យករបបសន្តតិកម្មដោយទទួលបន្តដោយស្វ័យប្រវត្តិទាំងសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដើម្បីឱ្យស្របទៅតាមទស្សនៈ និងស្ថានភាពក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន[17]។ ការអនុវត្តគោលការណ៍នេះ អាចចំណេញពេលវេលាច្រើនសម្រាប់សន្តតិជន ហើយនិងរួមចំណែក ក្នុងការសម្រាលបន្ទុករបស់តុលាការក្នុងការចំណាយពេលវេលាក្នុងការជម្រះបញ្ជីផងដែរ។ លើសពីនេះ ជាក់ស្តែងប្រជាពលរដ្ឋកម្ពុជាភាគច្រើនដែលមានទ្រព្យសម្បត្តិច្រើន អាចជ្រើសយកការប្រើមតកសាសន៍ធ្វើជានីតិវិធីទូទាត់ ដើម្បីសងបំណុលដោយទ្រព្យសម្បត្តិជាក់លាក់។

ដូចបានបញ្ជាក់ពីខាងលើ ដោយសារតែក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវបានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការពីប្រទេសជប៉ុន ទើបក្រមរដ្ឋប្បវេណីកម្ពុជា មានភាពស្រដៀងគ្នាច្រើនទៅនឹងក្រមរដ្ឋប្បវេណីជប៉ុន។ ហេតុនេះ របបសន្តតិកម្មនៃកម្ពុជា ក៏ដូចគ្នានឹងជប៉ុនដែរ គឺប្រកាន់យកគោលការណ៍ទទួលបន្តមត៌កដោយស្វ័យប្រវត្តិ[18]។

[17] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគទី៦, គន្ថីទី៨ ទី៩,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ១។

[18] តាកាហាស៊ីតូមូកុ, *នីតិរដ្ឋប្បវេណី ភាគទី៧ ស្តីពីញាតិ និងសន្តតិកម្ម, បោះពុម្ពលើកពី២,* (ឃឹហិកាគឹ, ឆ្នាំ២០០៩), ២២៨។

# ជំពូកទី២ ការចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម

នៅក្នុងជំពូកទី ២ នេះ ជាគោលដៅចម្បង គឺការបកស្រាយអំពីការចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម។ ការចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម ត្រូវបានបែងចែកជាពីរករណី គឺករណីសន្តតិកម្មមានមតកសាសន៍ និងករណីសន្តតិកម្មគ្មានមតកសាសន៍។

## ២.១. សន្តតិកម្មមានមតកសាសន៍

មតកសាសន៍ សំដៅទៅលើ "លិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។"[19] ដើម្បីឱ្យមតកសាសន៍មានសុពលភាព ត្រូវបំពេញលក្ខខណ្ឌពីរ គឺលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។ លក្ខខណ្ឌគ្រឹះ សំដៅលើការបង្ហាញឆន្ទៈពិតប្រាកដរបស់មតកជន។ រីឯលក្ខខណ្ឌទម្រង់វិញ សំដៅទៅលើបែបបទ និងសមាសភាពនៃអ្នកធ្វើមតកសាសន៍។ មតកសាសន៍អាចធ្វើបានតាមទម្រង់ធម្មតា[20] ដែលរួមមានមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន និងមតកសាសន៍ដោយលិខិតសម្ងាត់ និងទម្រង់ពិសេស[21]ផងដែរ។ គួរបញ្ជាក់ផងដែរថា ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍បានច្រើនដង និងអាចកែប្រែ ដោយផ្លាស់ប្តូរ ឬលុបចោលមតកសាសន៍មុនមួយភាគ ឬទាំងមូល នៅពេលណាក៏បានតាមទម្រង់នៃមតកសាសន៍អាស្រ័យលើឆន្ទៈរបស់ម្ចាស់បណ្តាំ។[22] "ប៉ុន្តែមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ។ នៅក្នុងករណីដែលមតកសាសន៍ ដែលគ្មានការចុះថ្ងៃខែឆ្នាំមានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនោះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។"[23] នេះមានន័យថា បើសិនជាមតកសាសន៍មានតែមួយ មតកសាសន៍នោះចាត់ទុកថាមានសុពលភាព។ បើមតកសាសន៍មានច្រើន ចាត់ទុកថាមានសុពលភាពទាំងអស់ បើសិនជាមតកសាសន៍ទាំងនោះគ្មានចំណុចផ្ទុយគ្នាទៅវិញទៅមកទេ។ ប៉ុន្តែ បើមតកសាសន៍ច្រើនដែលមិនបានចុះថ្ងៃខែឆ្នាំ ហើយមានចំណុចផ្ទុយគ្នា ដោយមិនដឹងថា មួយណាធ្វើមុន មួយណាធ្វើក្រោយ អានុភាពនៃមតកសាសន៍ទាំងនោះ ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។

---

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រទី ១៧។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៣ ដល់ ១១៧៥។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧ ដល់ ១១៨១។

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៨។

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៧០ កថាខណ្ឌ២។

មតកសាសន៍ចាប់មានអានុភាព នៅពេលម្ចាស់បណ្តាំបានទទួលមរណភាព។ ក្នុងករណីដែលមតកសាសន៍មានភ្ជាប់លក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌបង្អង់នោះត្រូវបានបំពេញក្រោយពេលដែលមតកជនបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាពចាប់ពីពេលដែលលក្ខខណ្ឌបង្អង់នោះត្រូវបានបំពេញ។

### ២.១.១. ការអនុវត្តតាមបណ្តាំមត៌ក

ជាគោលការណ៍ ឆន្ទៈរបស់មតកជនត្រូវតែគោរព និងអនុវត្តតាម លើកលែងតែមតកសាសន៍នោះ បានធ្វើឡើងដោយមានការបំពានទៅលើភាគបម្រុងរបស់សន្តតិជនណាម្នាក់ ហើយមានការតវ៉ាពីសន្តតិជននោះ។

#### ២.១.១.១. វិធីនៃការប្រតិបត្តិសន្តតិកម្មមានបណ្តាំមត៌ក

ទោះបីជាមានបណ្តាំមតិក (ឬមតកសាសន៍)ក៏ដោយ ពេលខ្លះបណ្តាំមតិកនោះ ត្រឹមត្រូវតាមទម្រង់ដែលពុំចោទជាបញ្ហានោះទេ ប៉ុន្តែពេលខ្លះខុសទៅនឹងទម្រង់ដែលជាមូលហេតុនាំឱ្យទទួលរងនូវមោឃៈ។

ក. បណ្តាំមតិកត្រឹមត្រូវតាមទម្រង់

"អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិកម្ម ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ។"[24] "បន្ថែមពីនេះ លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការដោយវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាងរបស់ជននោះ។"[25] នេះមានន័យថា អ្នករកឃើញមតកសាសន៍ក្រោយពេលដែលមតកជនបានទទួលមរណភាព ត្រូវដាក់ពាក្យសុំក្រោយពេលដែលខ្លួនបានរកឃើញលិខិតនោះ ដោយគ្មានការយឺតយ៉ាវ។ ម្យ៉ាងវិញទៀត មតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត មិនចាំបាច់សុំការបញ្ជាក់លិខិតនោះឡើយ[26] ដោយសារតែលិខិតនេះរក្សាទុកដោយសារការី ទទួលបាននូវជំនឿទុកចិត្តខ្ពស់ និងមានការទទួលខុសត្រូវដោយសារការី។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៣ កថាខណ្ឌ១។
[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៣ កថាខណ្ឌ៣។
[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២១៣ កថាខណ្ឌ២។

### ខ. បណ្តាំមតិកដែលមិនត្រឹមត្រូវតាមទម្រង់

"មតកសាសន៍ ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ"[27] មានន័យថា មតកសាសន៍អាចធ្វើបានតែក្នុងទម្រង់ណាមួយដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីថ្មីនេះប៉ុណ្ណោះ បើមិនដូច្នេះទេ នឹងចាត់ទុកថាគ្មានសុពលភាព។ បើមតកសាសន៍មិនធ្វើតាមទម្រង់ណាមួយដែលមានចែងនៅក្នុងក្រមនេះទេ នោះនឹងមិនអាចបញ្ជាក់បានទេថា មតកសាសន៍នោះបានធ្វើឡើងដោយមតកជនមែន ឬយ៉ាងណា ហើយមតកសាសន៍នោះពិតជាត្រូវបានផ្លាស់ប្តូរ ឬលុបចោលមែនឬយ៉ាងណា។ ហេតុដូច្នេះហើយ បានជាក្រមរដ្ឋប្បវេណីថ្មីកំណត់ដូចនេះ ដើម្បីបញ្ចៀសការកើតបញ្ហា ក្រោយពេលមតកជនទទួលមរណភាព។

ដោយសារតែមតកសាសន៍មិនត្រឹមត្រូវតាមទម្រង់ នាំឱ្យមតកសាសន៍ទទួលរងនូវមោឃៈ ហេតុនេះហើយសន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីឱ្យតុលាការធ្វើការបែងចែកដោយផ្អែកតាមច្បាប់។ នីតិវិធីក្នុងការអនុវត្តមតកសាសន៍ប្រភេទនេះ ដូចគ្នាទៅនឹងករណីគ្មានមតកសាសន៍ដែរ ដែលនឹងរៀបរាប់លម្អិតនៅចំណុច ២.២ ខាងក្រោមនេះ។

#### ២.១.១.២. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ

ទ្រព្យសម្បត្តិរបស់មតកជនទាំងចលនវត្ថុ និងអចលនវត្ថុ ត្រូវធ្លាក់មកសន្តតិជន ឬសហសន្តតិជនដោយស្វ័យប្រវត្តិ បន្ទាប់ពីមតកជនទទួលមរណភាព។[28] ក្រមរដ្ឋប្បវេណីថ្មី មិនកំណត់ឱ្យមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុឡើយ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែង ទោះបីជាសន្តតិជនទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចលើមតិកដោយស្វ័យប្រវត្តិក៏ដោយ ក៏មានភាពលំបាកក្នុងការបង្ហាញតតិយជនថា គាត់ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ដែរ។ ហេតុនេះហើយ ជាលក្ខណៈបច្ចេកទេសទាមទារឱ្យសន្តតិជនធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលវត្ថុដោយមូលហេតុសន្តតិកម្ម។

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រ១១៧០ កថាខណ្ឌ២ វាក្យខណ្ឌ១។

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៧ ចំណុច១។

### ក. សកម្មភាពរបស់អ្នកស្នើសុំចុះបញ្ជី

ដើម្បីឱ្យការចុះបញ្ជីទទួលជោគជ័យ អ្នកស្នើសុំចុះបញ្ជីត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួន។ ដំណាក់កាលមុនចុះបញ្ជីដែលធ្វើឡើងដោយអ្នកស្នើសុំចុះបញ្ជី មានបង្ហាញនៅក្នុងរូប១។

រូប១៖ ដំណាក់កាលមុនការចុះបញ្ជី



ក្រមរដ្ឋប្បវេណី មិនបានកំណត់ឱ្យមានការចុះបញ្ជីចំពោះការទទួលកម្មសិទ្ធិតាមរយៈសន្តតិកម្មនោះទេ ព្រោះមិនមែនជាការផ្ទេរសិទ្ធិតាមរយៈការព្រមព្រៀងដែលត្រូវអនុវត្តតាមមាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណីឡើយ តែដើម្បីទទួលបានលក្ខខណ្ឌតតាំងជាមួយតតិយជន អ្នកទទួលកម្មសិទ្ធិដោយមូលហេតុសន្តតិកម្ម ត្រូវធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។

ការអនុវត្តជាក់ស្តែង ចំពោះមតកសាសន៍ដែលត្រឹមត្រូវតាមទម្រង់ ជាពិសេសពាក់ព័ន្ធនឹងមតកសាសន៍ដែលមិនបានធ្វើឡើងដោយសារការី គឺសន្តតិជនតែងត្រូវបានបង្គាប់ឱ្យដាក់ពាក្យសុំទៅតុលាការបញ្ជាក់លើមតកសាសន៍សិន។ ករណីខ្លះទៀត ដោយមានយោគយល់ពីមន្ត្រីចុះបញ្ជី ប្រសិនបើមតកសាសន៍នោះ ពុំមានការជំទាស់ពីសន្តតិជនណាម្នាក់ទេ សហសន្តតិជនទាំងអស់ត្រូវចុះហត្ថលេខាដើម្បីបញ្ជាក់ពីការឯកភាពចំពោះមតកសាសន៍។ បន្ទាប់ពីចុះហត្ថលេខាយល់ព្រមរួច សន្តតិជនដែលមានបំណងចុះបញ្ជីអចលនវត្ថុ ត្រូវយកមតកសាសន៍នោះ រួមជាមួយពាក្យសុំចុះបញ្ជី ទៅមន្ទីរសុរិយោដី ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការឡើយ។ គួរកត់សម្គាល់ឱ្យឃើញថា ករណីដែលកើតឡើងជាញឹកញាប់គឺ ការឆ្លងកាត់នីតិវិធីតុលាការជាមុនសិន។

ចំពោះមតកសាសន៍ដែលត្រឹមត្រូវតាមទម្រង់ តែមានសន្តតិជនណាម្នាក់មិនឯកភាពលើមតកសាសន៍នោះ និងមតកសាសន៍ដែលមិនត្រឹមត្រូវតាមទម្រង់ សន្តតិជនដែលជាអ្នកស្នើសុំចុះបញ្ជី ត្រូវដាក់ពាក្យសុំបែងចែកមតិកទៅតុលាការ ដើម្បីឱ្យតុលាការចេញសេចក្តីសម្រេចលើការបែងចែកមតិកនោះជាមុនសិន ដែលវិធីបែងចែកនេះមានចែងលម្អិតនៅចំណុច ក នៃ ២.១.២.២ (វិធីបែងចែកមតិកតាមច្បាប់)។ ក្រោយពេលទទួលបានសេចក្តីសម្រេច អ្នកស្នើសុំចុះបញ្ជីត្រូវរងចាំកាលបរិច្ឆេទនៃការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ។ បន្ទាប់មក អ្នកស្នើសុំចុះបញ្ជី ត្រូវធ្វើពាក្យសុំទៅតុលាការដើម្បីឱ្យមន្ត្រីមានសមត្ថកិច្ចដែលទទួលបន្ទុក(ក្រឡាបញ្ជី) មានការបញ្ជាក់ភាពស្ថាពរលើសេចក្តីសម្រេចខាងលើ។ ក្រៅពីលិខិតបញ្ជាក់ពីភាពស្ថាពរលើសេចក្តីសម្រេចពីតុលាការ អ្នកស្នើសុំចុះបញ្ជីត្រូវភ្ជាប់ពាក្យសុំចុះបញ្ជី[29]ផងដែរ ដាក់ទៅមន្ទីរសុរិយោដី។

នៅពេលមានម្ចាស់សិទ្ធិលើសពីម្នាក់ ហើយមានសិទ្ធិដូចគ្នា អាចចុះបញ្ជីជាទម្រង់កម្មសិទ្ធិអវិភាគបាន ដោយសហសន្តតិជនត្រូវដាក់ពាក្យសុំចុះបញ្ជីរួមគ្នាទៅរដ្ឋបាលសុរិយោដី ឬ

[29] សូមមើលឧបសម្ព័ន្ធ១ សម្រាប់ទម្រង់នៃពាក្យសុំចុះបញ្ជី។

សហសន្តតិជនអាចជ្រើសរើសអ្នកតំណាងណាម្នាក់ក្នុងចំណោមសហសន្តតិជន ឱ្យដាក់ពាក្យសុំចុះបញ្ជីកម្មសិទ្ធិអវិភាគនេះបាន។[30]

"ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ"[31] ហើយត្រូវធ្វើឡើងរួមគ្នាដោយបុគ្គលមានសិទ្ធិចុះបញ្ជី ជាមួយនឹងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី ប៉ុន្តែចំពោះការផ្ទេរសិទ្ធិដោយមូលហេតុសន្តតិកម្ម លើកលែងតែអច្ច័យទាន អាចតម្រូវឱ្យមានតែភាគីម្ខាងបាន[32]។

ការអនុញ្ញាតបែបនេះ ដោយសារតែសន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់ ដូចនេះមានតែភាគីម្ខាងគត់ដែលនៅរស់ គឺសន្តតិជន។

គួរបញ្ជាក់ផងដែរថា មុនពេលដែលកម្ពុជាមានសេចក្តីសម្រេចឆ្នាំ ២០១៦ ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត អ្នកស្នើសុំចុះបញ្ជីមានកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រាជាមុនសិន។ បើមិនបានបង់ពន្ធប្រថាប់ត្រាទេ ការចុះបញ្ជីប្រកដជាពុំជោគជ័យដោយសារតែរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត នឹងលើកពាក្យសុំចុះបញ្ជីនោះចោល។ យ៉ាងណា មិញ បន្ទាប់ពីសេចក្តីសម្រេចនេះចូលជាធរមាន ការបង់ពន្ធប្រថាត្រាប់ចំពោះការផ្ទេរខាងលើ ត្រូវបានលើកលែង។

## ខ. សកម្មភាពរបស់មន្ត្រីចុះបញ្ជី

យោងតាមប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ស្ថាប័នដែលមានសមត្ថកិច្ចទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ។[33] ចំណែក ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ គឺរដ្ឋបាល

[30] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ១០ ចំណុច៤, ប្រការ ៨០, ៨១។

[31] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ៦ កថាខណ្ឌទី១។

[32] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ១០ ចំណុចទី១, ២។

[33] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ៥ ចំណុចទី១ កថាខណ្ឌ១។

សុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ។[34] ដំណាក់កាលបំព្រួញនៃការចុះបញ្ជីដែលធ្វើឡើងដោយមន្ត្រីចុះបញ្ជី មានបង្ហាញនៅក្នុងរូប ២។

រូប២៖ ដំណាក់កាលនៃការចុះបញ្ជី




[34] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ១០ ចំណុចទី២។

រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត និងរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតសៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងៗទៀត។ ចំពោះរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបានទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវផ្ញើពាក្យសុំនោះ និងឯកសារពាក់ព័ន្ធទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ ដោយគ្មានការយឺតយ៉ាវ។[35]

រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬលិខិតផ្ទុកផ្តាក់ ហើយការចុះបញ្ជីនូវចំណុចដែលត្រូវចុះបញ្ជី គឺត្រូវចុះនៅក្នុងសៀវភៅចុះបញ្ជីដែលពាក់ព័ន្ធ។[36] រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវបង្គាប់ឱ្យអ្នកដាក់ពាក្យសុំចុះបញ្ជីកែតម្រូវដោយកំណត់ពេលសមរម្យ ក្នុងករណីមានចំណុចខ្វះខាតផ្សេងៗដូចជា អ្នកដាក់ពាក្យសុំពុំបានផ្តល់ឯកសារដែលចាំបាច់ ឬ ពុំបានបង់ពន្ធសេវាផ្សេងៗ ទាក់ទងនឹងការចុះបញ្ជីជាដើម។[37] ក្នុងករណីដែលបុគ្គលដាក់ពាក្យសុំចុះបញ្ជី មិនបានកែតម្រូវតាមការបង្គាប់នូវចំណុចខ្វះខាតខាងលើ ឬករណីការសុំចុះបញ្ជីខុសសមត្ថកិច្ច ឬករណីការចុះបញ្ជីនោះបានធ្វើឡើងម្តងរួចហើយ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវលើកពាក្យសុំចុះបញ្ជីនោះចោល។ យ៉ាងណាមិញ នៅពេលដែលពាក្យសុំចុះបញ្ជីត្រឹមត្រូវគ្រប់ចំណុចហើយ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវចុះបញ្ជីនូវចំណុចដែលត្រូវចុះបញ្ជី នៅក្នុងសៀវភៅចុះបញ្ជីដែលពាក់ព័ន្ធ។[38]

### ២.១.២. ការមិនអនុវត្តតាមបណ្តាំមត៌ក

ការមិនអនុវត្តតាមបណ្តាំត្រង់ចំណុចនេះ មានន័យថាទោះជាមតកជនបានបន្សល់ឆន្ទៈរបស់ខ្លួនលើការការបែងចែកមត៌កតាមរយៈមតកសាសន៍ក៏ដោយ ក៏សហសន្តតិជនមានសិទ្ធិបែងចែកផ្សេងពីមតកសាសន៍នោះបាន ប្រសិនបើពួកគេមានការព្រមព្រៀងគ្នា។

---

[35] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ៥, ចំណុចទី១។

[36] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ៦ កថាខណ្ឌ២, ៣។

[37] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ៩។

[38] ប្រកាសអន្តរប្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ៦ កថាខណ្ឌ៣។

### ២.១.២.១. ការដោះស្រាយក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយក្រៅប្រព័ន្ធតុលាការ សំដៅដល់ការការចរចារ ឬការពិភាក្សារបស់ភាគី លើការបែងចែកមតិកដោយមិនពឹងផ្អែកលើសាវនាការរបស់តុលាការ។ ការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះ មិនសូវមានលក្ខណៈតានតឹងដូចការដោះស្រាយដោយតុលាការឡើយ ដោយសារតែការដោះស្រាយវិវាទមានការយោគយល់គ្នា សម្របសម្រួលនឹងគ្នា មិនមានការប្រឈមមុខដាក់គ្នាខ្លាំង ហើយមិនធ្វើឡើងជាសាធារណៈឡើយ។ ការដោះស្រាយប្រភេទនេះ នាំមកនូវគុណសម្បត្តិច្រើន ដោយសារភាគីអាចសន្សំសំចៃការចំណាយ និងចំណេញពេលវេលាបានច្រើន បើប្រៀបធៀបទៅនឹងការដោះស្រាយតាមប្រព័ន្ធតុលាការ។ បន្ថែមពីនេះ ភាគីទាំងសងខាងអាចរក្សាទំនាក់ទំនងបានល្អនាពេលអនាគត ដោយសារតែនេះគ្រាន់តែជាការចរចារគ្នាដើម្បីឈានទៅរកចំណុចរួមមួយ ហើយធ្វើឡើងជាលក្ខណៈឯកជន និងសម្ងាត់។ លើសពីនេះ ការដោះស្រាយក្រៅប្រព័ន្ធតុលាការ ក៏រួមចំណែកក្នុងការសម្រាលបន្ទុករបស់តុលាការផងដែរ។

ចំពោះការបែងចែកមតិក សហសន្តតិជនមានសិទ្ធិជ្រើសរើសយកការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះបាន។ មាត្រា ១២៦៦ថ្មី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តអំពីការបែងចែកមតិកដោយការពិភាក្សារវាងសហសន្តតិកម្ម ដោយចែងថា "សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមតិកនៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម"[39]។ មានន័យថា ក្រោយពីចាប់ផ្ដើមសន្តតិកម្មបានមួយខែ សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាគ្នា ដើម្បីបែងចែកមតិកនៅពេលណាក៏បាន ប៉ុន្តែជាក់ស្ដែង ការបែងចែកមតិកនេះត្រូវតែឱ្យប្រាកដថាធ្វើឡើងដោយសហសន្តតិជនទាំងអស់ រួមមានទាំងកូនរបស់មតកជនដែលមកពីអាពាហ៍ពិពាហ៍មុន និងកូនដែលមតកជនបានទទួលស្គាល់តាំងខ្លួននៅមានជីវិត។ គួរបញ្ជាក់ផងដែរថា ក្នុងចំណោមសហសន្តតិជនទាំងអស់ ទោះបីជាមានអ្នកដែលបានទទួលផលប្រយោជន៍ពិសេសច្រើនដែលនាំឱ្យមិនអាចទទួលសន្តតិកម្មបាន ក៏សន្តតិជននោះចាំបាច់ត្រូវមានវត្តមានក្នុងការបែងចែកមតិក ដើម្បីបញ្ជាក់អំពីការបែងចែកនេះ។ ឈានមកដល់វិធីនៃការបែងចែកមតិកវិញ ក្រោយមរណភាពរបស់មតកជន សហសន្តតិជនទាំងអស់ អាចធ្វើការបែងចែកមតិកបានដោយគ្មានទាក់ទងនឹងមតកសាសន៍។[40] ចំណុចនេះត្រូវបានបកស្រាយថា ជាការសម្រួលមតិក ពោលគឺក្នុងករណីដែលសហសន្តតិជនទាំងអស់ បានព្រមព្រៀងគ្នាក្នុងការបែងចែកមតិកតាមការពិភាក្សាទោះបីជា ខ្លឹមសារនៃការព្រមព្រៀងខុសពីវិធីបែងចែកមតិកដែលបានកំណត់ដោយមតកសាសន៍ក៏

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦៦ថ្មី កថាខណ្ឌ១ វាក្យខណ្ឌ១។

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦៦ថ្មី។

ដោយ គឺត្រូវធ្វើតាមការពិភាក្សានោះ ពីព្រោះតាមផ្លូវច្បាប់ ត្រូវបានបកស្រាយថា ការបែងចែកបែបនេះ ជាការដែលសហសន្តតិជនបានធ្វើប្រទានកម្ម ឬប្តូរទ្រព្យគ្នាទៅវិញទៅមក បន្ទាប់ពីមតិកត្រូវបានធ្លាក់ទៅលើសន្តតិជនជាក់លាក់ តាមរយៈមតកសាសន៍នោះ។

ម៉្យាងវិញទៀត "ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមតិក ការបែងចែកត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ដូចជាលិខិតជាលាយល័ក្ខណ៍អក្សរជាអាទិ៍"។[41] ការកំណត់បែបនេះ ដោយសារតែ មានមតិកខ្លះត្រូវការមានទម្រង់កំណត់មួយដើម្បីផ្ទេរសិទ្ធិ ឬដើម្បីឱ្យមានលក្ខខណ្ឌតតាំង។ ប្រសិនបើមិនធ្វើតាមនីតិវិធីខាងលើនេះទេ ទោះបីជាសន្តតិជនផ្សេងទៀតបានព្រមព្រៀងបែងចែកមតិកដោយផ្ទាល់មាត់ក៏ដោយ អាចនឹងមានការវាយតម្លៃថា ការពិភាក្សាបែងចែកមតិកនោះមិនបានធ្វើឡើងរវាងសហសន្តតិជនទេ ជាហេតុចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមតិក។

ចំពោះការអនុវត្តជាក់ស្តែងរបស់ប្រជាពលរដ្ឋភាគច្រើន បន្ទាប់ពីសហសន្តតិជនទាំងអស់បានព្រមព្រៀងគ្នាលើការបែងចែកមតិកហើយ ពួកគេបានទៅជួបមេឃុំ ឬមេភូមិដើម្បីឱ្យជួយបញ្ជាក់ពីភាពដឹងលឺលើការព្រមព្រៀងនោះ។ បន្ទាប់ពីមានកិច្ចព្រមព្រៀងរវាងសហសន្តតិជនទាំងអស់លើការបែងចែកមតិក និងបានធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិរួច នីតិវិធីបន្ទាប់គឺសហសន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីទទួលបានសេចក្តីសម្រេច។

ករណីដែលបានរៀបរាប់ខាងលើនេះ គឺជាករណីដែលមានការព្រមព្រៀងលើការបែងចែកមតិករវាងសហសន្តតិជនទាំងអស់។ យ៉ាងណាមិញ ក្នុងករណីដែលការព្រមព្រៀងពុំទទួលបានលទ្ធផលទេ មានន័យថាសហសន្តតិជនពុំមានការព្រមព្រៀងគ្នាលើការបែងចែកមតិកទេ នោះសហសន្តតិជនត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឱ្យតុលាការធ្វើការបែងចែកលើមតិក។

### ២.១.២.២. ការដាក់ពាក្យសុំទៅតុលាការ

ក្រោយពីបញ្ចប់នីតិវិធីនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការ នីតិវិធីបន្ទាប់ គឺការដាក់ពាក្យសុំទៅតុលាការ។ ដូចបានរៀបរាប់ខាងលើ ទោះបីជាការព្រមព្រៀងលើការបែងចែកមតិករវាងសហសន្តតិជនទទួលបានជោគជ័យ ឬបរាជ័យក៏ដោយ ក៏សហសន្តតិជនត្រូវដាក់ពាក្យសុំមកតុលាការផងដែរ។

[41] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦៦ថ្មី ចំណុចទី២។

ចំពោះពាក្យបណ្តឹងនេះ តុលាការនឹងពិនិត្យមើលទៅលើការពិភាក្សារវាងសហសន្តតិជនជាមុនសិន ថាតើមានព្រមព្រៀងគ្នាដែរឬទេ។ ចំពោះករណីដែលមានការព្រមព្រៀងរវាងសហសន្តតិជន តុលាការនឹងពិនិត្យមើលបន្ថែមទៀត ថាតើការព្រមព្រៀងនេះកើតចេញពីឆន្ទៈរបស់សហសន្តតិជនពិតប្រាកដដែរឬទេ ថាតើប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈដែរឬទេ។ ប្រសិនបើតុលាការបានផ្ទៀងផ្ទាត់ឃើញពីភាពត្រឹមត្រូវពិតប្រាកដនៃការព្រមព្រៀងនេះ តុលាការនឹងចេញសេចក្តីសម្រេចបញ្ជាក់ពីភាពត្រឹមត្រូវនៃការព្រមព្រៀង លើការបែងចែកមត៌ករបស់សហសន្តតិជន។

ម្យ៉ាងវិញទៀត ចំពោះករណីដែលតុលាការពិនិត្យឃើញថា ការពិភាក្សារបស់សហសន្តតិជនលើការបែងចែកមត៌កពុំទទួលបានជោគជ័យទេ តុលាការនឹងពិនិត្យមើល ថាតើមានមតកសាសន៍ដែរឬទេ។ ប្រសិនបើមានមតកសាសន៍ ហើយមតកសាសន៍នោះត្រឹមត្រូវ តុលាការនឹងចេញសេចក្តីសម្រេចឱ្យអនុវត្តតាមមតកសាសន៍នោះ។ ផ្ទុយទៅវិញ បើសិនជា មតកសាសន៍ពុំត្រឹមត្រូវតាមទម្រង់ដែលកំណត់ដោយក្រមនេះទេ តុលាការនឹងធ្វើការបែងចែកជាថ្មីតាមច្បាប់។

## ក. វិធីបែងចែកមត៌កតាមច្បាប់

ក្នុងករណីគ្មានបណ្តាំមត៌ក ច្បាប់កំណត់ថា មត៌កត្រូវចែកទៅឱ្យសន្តតិជនដែលមានលំដាប់ ៣ថ្នាក់៖

"ប្រសិនបើមតកជនមានកូន កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី១"[42] មានន័យថា មត៌កត្រូវបានទៅកូនដែលមានបុត្តភាពដែលបានទទួលស្គាល់តាមផ្លូវច្បាប់។ គួរបញ្ជាក់ផងដែរថា កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា។[43] បើសិនជា មានសន្តតិជនណាមួយបានស្លាប់ ឬបាត់បង់សិទ្ធិជាសន្តតិជន ដោយសារបានក្លាយជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬត្រូវបានផ្តាច់មតកពីសន្តតិជន កូនរបស់សន្តតិជននោះ ត្រូវក្លាយជាសន្តតិជនជំនួស[44] មានន័យថា ចំណែកមត៌កនោះ ត្រូវផ្ទេរទៅឱ្យកូនៗរបស់សន្តតិជនដែលបានស្លាប់នោះ។

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៦ ចំណុចទី១។
[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៦ ចំណុចទី២។
[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៧ថ្មី។

ប្រសិនបើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន។[45] នេះមានន័យថា បើមតកជនមិនមានកូនសោះ មតិកត្រូវបានទៅឪពុកម្តាយរបស់មតកជន។ ក្នុងករណីគ្មានឪពុកម្តាយ មតិកត្រូវបានទៅជីដូនជីតារបស់មតកជន។ ម្យ៉ាងវិញទៀត ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗ ត្រូវទទួលចំណែកមតិកស្មើៗគ្នា[46]។

ប្រសិនបើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន[47] ពោលគឺបើមតកជនគ្មានទាំងកូន ហើយឪពុកម្តាយក៏ស្លាប់អស់ទៀត មតិកត្រូវបានទៅបងប្អូនបង្កើតរបស់មតកជន ដែលជាសន្តតិជនលំដាប់ទី៣។

ចំពោះសហព័ទ្ធ(ប្តី ឬប្រពន្ធ) របស់មតកជនវិញ គឺជាសន្តតិជនជានិច្ច[48] មានន័យថា ទោះបីជាមានសន្តតិជនស្ថិតក្នុងលំដាប់ណាមួយ ក្នុងលំដាប់សន្តតិជនទាំង៣ខាងលើ ក៏សហព័ទ្ធត្រូវមានចំណែកមតិកដែរ។

"ក្នុងករណីដែលសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗរបស់មតកជននោះ នឹងត្រូវទទួលចំណែកមតកិស្មើគ្នា"[49] មានន័យថា សហព័ទ្ធទទួលបានចំណែក ១ភាគ ២ ហើយចំណែក ១ភាគ ២ ទៀតជារបស់បច្ឆាញាតិរបស់មតកជន។ ជាឧទាហរណ៍ ក ដែលជាមតកជនបានបន្សល់ទុកប្រាក់ចំនួន ១០ ម៉ឺនដុល្លា។ មតកជន មានសហព័ទ្ធ និងកូន ២ នាក់។ ដូចនេះ សហព័ទ្ធត្រូវទទួលបាន៥ម៉ឺនដុល្លា ឯកូនទាំង២ទទួលបានចំណែកដែលនៅសល់ គឺ ៥ ម៉ឺនដុល្លា។

"ក្នុងករណីសហព័ទ្ធ និងឪពុក ម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមតិករបស់សហព័ទ្ធ ត្រូវជា ១ ភាគ៣ ចំណែកឯមតិករបស់ឪពុកម្តាយ ត្រូវជា ២ ភាគ៣។ ប៉ុន្តែ បើឪពុក ឬម្តាយរបស់មតកជនតែម្នាក់នៅរស់ ឪពុកម្តាយនោះ និងសហព័ទ្ធ ត្រូវបានចំណែកមតិកស្មើគ្នា"[50] មានន័យថាម្នាក់ៗទទួលបានទ្រព្យស្មើៗគ្នា។ ជាឧទាហរណ៍ មតកជន A គ្មានកូនទេ មានតែ

---

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៩ ចំណុចទី១។
[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៩ ចំណុចទី២។
[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦០ ចំណុចទី១។
[48] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១ ចំណុចទី១។
[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦២ ចំណុច ក។
[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦២ ចំណុច ខ។

សហាព័ទ្ធ B និងឪពុក ម្តាយ C និងD។ A បានបន្សល់ទុកប្រាក់ ៦ ម៉ឺនដុល្លា។ ក្នុងករណីនេះ B ត្រូវទទួលបាន ២ ម៉ឺនដុល្លា ហើយ C និងD ទទួលបានទ្រព្យដែលនៅសល់ គឺ ៤ ម៉ឺនដុល្លា។ តែបើ C ដែលជាឪពុក បានទទួលមរណភាព នោះសហាព័ន្ធ B និងម្តាយ D បានទទួលចំណែកស្មើគ្នា គឺម្នាក់ៗទទួលបាន ៣ ម៉ឺនដុល្លា។

ក្នុងករណីសហាព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមតិករបស់សហាព័ទ្ធ ត្រូវជា ១ ភាគ២ ហើយអ្នកផ្សេងទៀត ទទួលបានចំណែក ១ ភាគ២។[51] ជាឧទាហរណ៍មតកជន A គ្មានកូនទេ ហើយឪពុក ម្តាយក៏បានស្លាប់ មានតែសហាព័ទ្ធ B និងបងប្អូនបង្កើត C និង D។ A បានបន្សល់ទុកប្រាក់ ៦ ម៉ឺនដុល្លា។ ដូចនេះ សហាព័ទ្ធ B ត្រូវទទួលបានចំណែក ៣ ម៉ឺនដុល្លា ហើយ C និងD ត្រូវទទួលបានចំណែកពាក់កណ្តាលទៀតដែលនៅសល់គឺ ៣ ម៉ឺនដុល្លា។

#### ២.១.២.៣. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ

នីតិវិធីនៃការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុត្រង់ចំណុចនេះ ដូចគ្នានឹងករណីមតកសាសន៍មិនត្រឹមត្រូវតាមទម្រង់ដែរ ដែលបានរៀបរាប់ក្នុងចំណុច ២.១.១.២ ខាងលើ។

## ២.២. សន្តតិកម្មគ្មានមតកសាសន៍

សន្តតិកម្មគ្មានមតកសាសន៍ មានលក្ខណៈផ្ទុយនឹងសន្តតិកម្មមានមតកសាសន៍ ពោលគឺជាផ្ទេរមតិកទៅឱ្យសន្តតិជនរបស់មតកជន ប៉ុន្តែមតកជននោះពុំបានបន្សល់ទុកនូវឆន្ទៈ ឬមតកសាសន៍លើការបែងចែកមតិកឡើយ។ ដូចនេះ ការបែងចែកមតិក អាចធ្វើឡើងតាមរបៀបពីរយ៉ាង គឺការបែងចែកមតិកដោយការព្រមព្រៀងរវាងសហសន្តតិជទាំងអស់ និងការបែងចែកមតិកដោយប្រព័ន្ធតុលាការ។

### ២.២.១. ការបែងចែកដោយការព្រមព្រៀងរវាងសហសន្តតិជនទាំងអស់

ករណីដែលគ្មានមតកសាសន៍ ពុំមានភាពស្មុគស្មាញដូចករណីមានមតកសាសន៍ទេ។ ដំបូងក្រោយពេលដែលមតកសាសន៍បានចាប់ផ្តើម សហសន្តតិជនទាំងអស់គួរពិភាក្សាគ្នាដើម្បីស្វែងរកការព្រមព្រៀងពីសហសន្តតិជនទាំងអស់ មុនឈានទៅដល់ការដោះស្រាយដោយប្រព័ន្ធតុលាការ។ ការពិភាក្សាស្វែងរកការឯកភាពគ្នារវាងសហសន្តតិជននេះ ធ្វើឱ្យភាគីចំណាយថវិការតិច នីតិវិធីប្រើរយៈពេលខ្លី និងរក្សាទំនាក់ទំនងគ្នាបានទៅថ្ងៃក្រោយ។ ដោយសារតែគ្មានមតកសាសន៍ សន្តតិជន

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦២ ចំណុច គ។

ត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីសុំបញ្ជាក់ទាយាទ និងបែងចែកមតិក។[52] ក្រោយពេលដែលតុលាការពិនិត្យឃើញត្រឹមត្រូវគ្រប់ចំណុចហើយ តុលាការនឹងចេញដីការសម្រេចទទួលស្គាល់ចំពោះការទាមទាររបស់ភាគីអ្នកដាក់ពាក្យសុំ។

#### ២.២.១.១. ការធ្វើឯកសារសម្រាប់ចុះបញ្ជីផ្ទេរអចលនវត្ថុ

ក្រោយពេលដែលដីការសម្រេចខាងលើចូលជាស្ថាពរ សន្តតិជនត្រូវដាក់ពាក្យសុំចុះបញ្ជីអចលនវត្ថុដើម្បីទទួលបានលក្ខខណ្ឌតតាំងជាមួយតតិយជន។ ដើម្បីចុះបញ្ជីផ្ទេរអចលនវត្ថុបានទាមទារឱ្យសហសន្តតិជនដាក់ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយឯកសារចាំបាច់មួយចំនួនទៀត[53] ដូចជា ឯកសារដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី និងសាលក្រម ឬសាលដីកាស្ថាពរជាអាទិ៍ក្នុងករណីដែលពាក្យសុំចុះបញ្ជីត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬសាលដីកាស្ថាពរជាដើម។

#### ២.២.១.២. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ

នីតិវិធីនៃការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុត្រង់ចំណុចនេះ ដូចគ្នានឹងនីតិវិធីនៅត្រង់ចំណុច ២.១.១.២ ខាងលើនេះដែរ។

### ២.២.២. ការបែងចែកដោយតុលាការ

បើសិនជាការពិភាក្សារវាងសហសន្តតិជន ចំពោះការការបែងចែកមតិក ពុំបានសម្រេច ឬពុំអាចពិភាក្សាបានទេ សន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមតិកនោះបាន។[54] គួរបញ្ជាក់ផងដែរថា តុលាការមិនអាចធ្វើការបែងចែកដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានទេ ពោលគឺលុះត្រាតែមានការដាក់ពាក្យសុំពីសហសន្តតិជនតែប៉ុណ្ណោះ។

#### ២.២.២.១. មូលហេតុនៃការដាក់ពាក្យសុំ

នៅពេលដែលសន្តតិកម្មចាប់ផ្តើមមានអត្ថិភាព បុគ្គលដែលយល់ថាខ្លួនជាសន្តតិជនស្របច្បាប់មានសិទ្ធិក្នុងការទាមទារនូវចំណែករបស់ខ្លួន ស្របតាមការកំណត់របស់ច្បាប់។ វិធីដើម្បីសម្រេចសិទ្ធិនៃការទាមទាររបស់ខ្លួនត្រង់ចំណុចនេះ ប្រសិនបើសហសន្តតិជនទាំងអស់មិនបានព្រមព្រៀងគ្នាដូចចំណុច ២.២.១ ខាងលើទេ គឺរបៀបរៀបចំពាក្យសុំទៅតុលាការ ដោយលើកយក

[52] សូមមើលឧបសម្ព័ន្ធ២ សម្រាប់ឧទាហរណ៍(ដីកាសម្រេចរបស់តុលាការលើការសុំបញ្ជាក់ទាយាទ និងបែងចែកមតិក)។

[53] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣, ប្រការ ២៧។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៧០។

មូលហេតុនៃវិវាទរបស់សហសន្តតិជនទាំងអស់ឱ្យតុលាការពិនិត្យ និងសម្រេច។ មូលហេតុសំខាន់នៃវិវាទក្នុងករណីសន្តតិកម្មនេះមានពីរ គឺទី១ ពាក់ព័ន្ធនឹងបញ្ហាអត្ថិភាព ឬនត្ថិភាពនៃសន្តតិជន ក្នុងករណីដែលមានភាពមិនច្បាស់រវាង ទំនាក់ទំនងរបស់មតកជននិងសន្តតិជន និងទី២ គឺពាក់ព័ន្ធនឹងការទាមទារឱ្យបែងចែកមតិកក្នុងករណីដែលសហសន្តតិជនខ្វែងគំនិត ឬមានវិវាទរវាងគ្នាលើចំណែកនៃមតិក ដែលខ្លួននឹងត្រូវទទួលបាន។

### ២.២.២.២. ការរៀបចំពាក្យសុំ និងភស្តុតាងបញ្ជាក់សម្រាប់តុលាការពិនិត្យ

ដើម្បីរៀបចំពាក្យសុំក្នុងរឿងក្តីរដ្ឋប្បវេណីបានត្រឹមត្រូវ ដើមចោទចាំបាច់ត្រូវសរសេរ នូវចំណុចសំខាន់មួយចំនួន ដូចជា ៖ អត្តសញ្ញាណរបស់ភាគីដើមចោទ និងចុងចម្លើយ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់បញ្ជាក់នូវការទាមទារ ។ ក្រៅពីនេះ ដើមចោទក៏អាចបញ្ជាក់ឱ្យកាន់តែច្បាស់ នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងបញ្ជាក់លើការទាមទារ[55]។ ដោយឡែកចំពោះបណ្តឹងពាក់ព័ន្ធនឹងសន្តតិកម្មនេះ ដើម្បីទទួលបានជោគជ័យ ត្រូវរៀបចំដូចខាងក្រោម ៖

- អត្តសញ្ញាណភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ៖ អ្នកដាក់ពាក្យបណ្តឹងជាដើមចោទ ហើយសន្តតិជនផ្សេងទៀត ឬអ្នកតំណាងស្របច្បាប់របស់សន្តតិជនដែលមានវិវាទជាមួយដើមចោទ ជាចុងចម្លើយ។ ការសរសេរបញ្ជាក់ត្រង់ចំណុចនេះ គឺត្រូវសរសេរ ឈ្មោះ ភេទ អាយុ ដើម្បីបញ្ជាក់ពី សមត្ថភាពភាគីនៃបណ្តឹង និងសរសេរអំពីអាស័យដ្ឋានរបស់ភាគី ដើម្បីឱ្យតុលាការងាយស្រួលក្នុងការធ្វើការបញ្ជូន។
- ខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ ៖ អនុឡោមតាមចំណុច ២.២.២.១ ខាងលើដើមចោទត្រូវសរសេរចំណុចនេះថា ៖ ទី១-សុំឱ្យតុលាការបញ្ជាក់អត្ថិភាពជាសន្តតិជនលើមតិករបស់មតកជនឈ្មោះ .... និងទី២-សុំឱ្យតុលាការបែងចែកចំណែក សន្តតិកម្មរបស់មតកជនឈ្មោះ ...... តាមច្បាប់ រវាងដើមចោទ និងចុងចម្លើយ។ គួរបញ្ជាក់ផងដែរថា បើចំណុចទី១ គ្មានវិវាទទេ ចំណុចនេះមិនចាំបាច់ធ្វើការស្នើសុំទេ។
- មូលហេតុចាំបាច់បញ្ជាក់ការទាមទារ ៖ ចំណុចនេះគឺជាមូលដ្ឋានគតិយុត្ត ដែលជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទ ហើយក្នុងករណីនៃបណ្តឹងពាក់ព័ន្ធនឹងសន្តតិកម្ម ចំណុចនេះត្រូវរំលេចឱ្យឃើញថា ដើមចោទជាសន្តតិជនស្របច្បាប់ មានអត្ថិភាពនៃសន្តតិកម្មកើតឡើង។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥ របៀបនៃការដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង។

- អង្គហេតុជាមូលហេតុនៃការទាមទារ ៖ ចំណុចនេះ ច្បាប់មិនតម្រូវថាត្រូវតែសរសេរទេ។ ដូច្នេះដើមចោទមានជម្រើសសរសេរក៏បាន មិនសរសេរក៏បាន។ ប៉ុន្តែការសរសេរ គឺមាន ផលចំណេញ ដោយសារតុលាការនឹងឆាប់យល់នូវរឿងហេតុទាំងមូលនៃបណ្តឹង ហើយចំណុចនេះក៏អាចដើរតួជា ឯកសារត្រៀមផងដែរ។ ដើម្បីសរសេរចំណុចនេះបានល្អ ដើមចោទត្រូវបញ្ជាក់ដំណើររឿងទាំងមូល។

- ភស្តុតាង ៖ នេះជាការចង្អុលបញ្ជាក់ថា ការអះអាងរបស់ដើមចោទមិនមែនចេះតែធ្វើឱ្យរួចពីដៃនោះទេ គឺមានការបញ្ជាក់ច្បាស់លាស់ដោយភស្តុតាង ជាឯកសារ សាក្សី រូបថត វីដេអូជាដើម។ ការសរសេរបញ្ជាក់ភស្តុតាងនៅពាក្យបណ្តឹងក៏មិនមែនជាភាពចាំបាច់ដែរ ពីព្រោះនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រោយពេលកំណត់ ចំណុចវិវាទបានរួចរាល់ តុលាការនឹងរៀបចំភស្តុតាងបំភ្លឺលើចំណុចវិវាទម្តងទៀត។ នៅក្នុងរឿងក្តីនៃសន្តតិកម្ម ភស្តុតាងដែលគួរភ្ជាប់នៅក្នុងពាក្យបណ្តឹងរួមមាន ៖

  - លិខិតមរណភាពរបស់មតកជន
  - ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ភាគីនីមួយៗ មានដូចជាអត្តសញ្ញាណប័ណ្ណ, លិខិតឆ្លងដែន
  - ឯកសារបញ្ជាក់ពីអត្ថិភាពរបស់សន្តតិជន មានដូចជា សំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅជាដើម
  - ឯកសារបញ្ជាក់ពីទ្រព្យ ដែលជាកម្មវត្ថុនៃសន្តតិកម្ម។

### ២.២.២.៣. ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុបន្ទាប់ពីមានសេចក្តីសម្រេចរបស់តុលាការ

ក្រោយពេលពាក្យសុំបានដាក់ តុលាការនឹងចាត់ការតាមនីតិវិធី រហូតដល់ចេញសេចក្តីសម្រេចបញ្ចប់ តាមរយៈសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលសម្រេចតាមការទាមទារ ឬបដិសេធការទាមទារ។ ដោយឡែក ក្នុងករណីដែលតុលាការសម្រេចតាមការទាមទារ ហើយបែងចែកមតិកជាអចលនវត្ថុឱ្យភាគីនៃបណ្តឹង ក៏មិនទាន់មានន័យថា អ្នកទទួលបាននោះអាចទទួលបានសិទ្ធិកម្មសិទ្ធិលើអចលវត្ថុមួយរយភាគរយដែរ គឺគាត់ចាំបាច់ធ្វើការចុះបញ្ជីនៅមន្ទីរសុរិយោដី។ ក្រោយពេលចុះបញ្ជីរួចរាល់ ទើបគាត់អាចក្លាយជាម្ចាស់កម្មសិទ្ធិករពេញលេញលើអចលនវត្ថុ ដែលទទួលបានពីសន្តតិកម្មកំណត់ដោយសេចក្តីសម្រេច។[56] ចំពោះការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៧, អានុភាពក្នុងការសន្ទត់នៃការចុះបញ្ជី។

បន្ទាប់ពីមានសេចក្តីសម្រេចរបស់តុលាការត្រង់ចំណុចនេះ សូមមើលចំណុច ២.១.១.២ ការស្នើសុំចុះបញ្ជីផ្ទេរអចលនវត្ថុ។

សកម្មភាព និងការរៀបចំខាងលើ គឺអនុវត្តដោយអនុឡោមតាមមាត្រា ៥២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសអន្តរក្រសួងឆ្នាំ ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។ ប៉ុន្តែការអនុវត្តជាក់ស្តែងគឺហាក់មិនបានដើរតាមវិធីនេះទេ ដោយសារតែភាគីដែលមានបំណងចុះបញ្ជីគ្រាន់តែយកពាក្យសុំអនុវត្តទៅដាក់នៅតុលាការ តុលាការសម្រួលដោយចេញកំណត់ហេតុ អនុវត្តលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី បញ្ជូនឯកសារទាំងនោះទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់តាមរយៈដីកាបញ្ជូន។

ឆ្លងតាមការបកស្រាយខាងលើ ការចុះបញ្ជីផ្ទេរអចលនវត្ថុតាមរយៈសន្តតិកម្ម អាចប្រព្រឹត្តទៅបាន ទាំងករណីសន្តតិកម្មមានមតកសាសន៍ និងករណីសន្តតិកម្មគ្មានមតកសាសន៍។ ទោះបីជាករណីសន្តតិកម្មមានមតកសាសន៍ និងករណីសន្តតិកម្មគ្មានមតកសាសន៍អាចប្រព្រឹត្តទៅបានដូចគ្នា ប៉ុន្តែតម្រូវឱ្យឆ្លងកាត់នីតិវិធីអនុវត្តស្មុគស្មាញខុសៗគ្នា មុននឹងឈានទៅដល់ការចុះបញ្ជីបាន។ ករណីសន្តតិកម្មមានមតកសាសន៍ សន្តតិជនអាចជ្រើសរើសបានថាអនុវត្ត ឬមិនអនុវត្តតាម។ ចំណែកឯ ករណីសន្តតិកម្មគ្មានមតកសាសន៍ សហសន្តតិជនអាចបែងចែកគ្នាបានដោយការពិភាក្សាដើម្បីឈានទៅរកការព្រមព្រៀងគ្នា។ ប្រសិនបើ ការពិភាក្សាពុំទទួលបានជោគជ័យ សហសន្តតិជនអាចដាក់ពាក្យទៅតុលាការដើម្បីបែងចែកលើមតិកនោះ។

# ជំពូកទី៣ បញ្ហាប្រឈម

## ៣.១. អចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី

ការចុះបញ្ជីអចលនវត្ថុ គឺជាសកម្មភាពនៃការចុះទៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ដោយអាជ្ញាធរមានសមត្ថកិច្ច នូវស្ថានភាពរូបសាស្ត្រនៃអចលវត្ថុ ជាអាទិ៍ លេខក្បាលដី ទីតាំង ទំហំ និងព្រំប្រទល់ ជាមួយអត្តសញ្ញាណនៃបុគ្គលដែលមានសិទ្ធិទៅលើអចលវត្ថុនោះ។ បន្ទាប់មក អាជ្ញាធរនឹងប្រគល់ប័ណ្ណសម្រាប់សម្គាល់កម្មសិទ្ធិដែលបានចុះបញ្ជីនោះ ដល់អ្នកដែលមានឈ្មោះនៅក្នុងប័ណ្ណ សម្រាប់គាត់យកទៅប្រើប្រាស់ដូចជា ការតតាំងជាមួយតតិយជន(អ្នកមានបំណងរំលោភសិទ្ធិ) ឬដាក់ធានាបំណុល(កិច្ចសន្យាប្រាតិភោគ)ជាដើម។

ទោះបីជាការចុះបញ្ជីអចលនវត្ថុមានសារប្រយោជន៍ និងគុណតម្លៃ ដែលបានធ្វើឱ្យប្រតិបត្តិការអចលនវត្ថុរលូនក៏ដោយ កម្ពុជានៅមិនទាន់ដោះស្រាយបញ្ហាដីធ្លីរួចនៅឡើយ និយាយរួមមានតែ អចលនវត្ថុមួយចំនួនតូចប៉ុណ្ណោះត្រូវបានចុះបញ្ជីរួច ហើយមួយចំនួនផ្សេងទៀតនៅមិនទាន់បានចុះបញ្ជីនៅឡើយ។ ដើម្បីឱ្យយល់ច្បាស់លើចំណុចនេះ ចាំបាច់ត្រូវធ្វើការស្វែងយល់ឱ្យខានតែបានអំពី ៖ មូលហេតុដែលនាំឱ្យប្រជាពលរដ្ឋមិនទៅចុះបញ្ជីអចលនវត្ថុពេលទទួលបានពីអចលនវត្ថុតាមរយៈសន្តតិកម្ម ផលវិបាកនៃការមិនទៅចុះបញ្ជី និងដំណោះស្រាយលើផលវិបាកទាំងនោះ។

### ៣.១.១. មូលហេតុនៃការមិនទៅចុះបញ្ជីបន្ទាប់ពីទទួលបានមត៌ក

តាមរយៈការសិក្សា និងពិនិត្យទៅលើតថភាពនៃសង្គម បានបង្ហាញឃើញថា មូលហេតុដែលប្រជាពលរដ្ឋមិនទៅចុះបញ្ជីអចលនវត្ថុ បន្ទាប់ពីគាត់ទទួលបានមត៌កតាមរយៈសន្តតិកម្ម មានប្រភពចេញពីដើមចមសំខាន់ពីរគឺ ចំណេះដឹង និងផ្នត់គំនិតរបស់ប្រជាពលរដ្ឋផ្ទាល់ និងភាពមិនច្បាស់លាស់នៃយន្តការរបស់រដ្ឋ។

#### ៣.១.១.១. ចំណេះដឹង និងផ្នត់គំនិតរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋ ដែលរស់នៅជនបទ ភាគច្រើនពុំបានយល់ដឹងពីសារៈសំខាន់នៃការចុះបញ្ជី និងប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី ដែលជាការធានាសុវត្ថិភាពដីធ្លី សិទ្ធិជាកម្មសិទ្ធិករ សិទ្ធិប្រើប្រាស់ដីធ្លី និងសិទ្ធិផ្សេងៗជាច្រើនទៀតឡើយ ជាហេតុធ្វើឱ្យពួកគាត់ពុំបានយល់ចិត្តទុកដាក់ក្នុងការចុះបញ្ជី។ ពួកគាត់គិតថា អចលនវត្ថុដែលគាត់ទទួលបាន បានបន្សល់ទុកតៗគ្នាឱ្យកូនចៅពីមួយជំនាន់ ទៅមួយជំនាន់ ដោយមិនធ្លាប់ឆ្លងកាត់ការចុះបញ្ជី ដូចនេះគាត់ក៏មិនចាំបាច់ចុះបញ្ជីដែរ។ មូលហេតុផ្សេងទៀត គាត់យល់ឃើញថា អចលនវត្ថុរបស់គាត់ទុកសម្រាប់កូនចៅរបស់គាត់តែប៉ុណ្ណោះ

ដោយពុំមានបំណងលក់ដូរអ្វីឡើយ។ ដូចនេះ គ្មានហេតុផលអ្វីដែលគាត់ចាំបាច់ចំណាយលុយលើការចុះបញ្ជីទេ។ មូលហេតុសំខាន់មួយទៀត ពួកគាត់អាចនឹងគិតថា ការចុះបញ្ជីទាមទារពេលវេលា និងមាននីតិវិធីស្មុគស្មាញ ដែលជាផលលំបាកមួយសម្រាប់ពួកគាត់។ ដូចនេះ ប្រសិនបើពួកគាត់ទៅចុះបញ្ជី អាចនឹងខាតបង់ដល់ការប្រកបរបរប្រចាំថ្ងៃរបស់គាត់។ ដោយឡែក ប្រជាពលរដ្ឋមួយចំនួន ជាពិសេសប្រជាពលរដ្ឋដែលរស់នៅជនបទ ឬទីដាច់ស្រយាល ពុំមានលទ្ធភាពក្នុងការបង់ពន្ធប្រថាប់ត្រាឡើយ ដោយសារតែពន្ធប្រថាប់ត្រាមានតម្លៃខ្ពស់សម្រាប់ពួកគាត់ រួមផ្សំជាមួយពួកគាត់មានជីវភាពប្រចាំថ្ងៃខ្វះខាតផង។

### ៣.១.១.២. ភាពមិនច្បាស់លាស់នៃយន្តការរបស់រដ្ឋ

ពេលបច្ចុប្បន្ន នៅប្រទេសកម្ពុជាមានតែនីតិវិធីក្នុងការចុះបញ្ជីដែលតម្រូវឱ្យភាគីដាក់ពាក្យសុំនៅមន្ទីរសុរិយោដី ប៉ុន្តែពុំទាន់មានយន្តការណាមួយបានចែងច្បាស់នៅឡើយ អំពីនីតិវិធីផ្ទេរកម្មសិទ្ធិអចលនទ្រព្យដោយមូលហេតុសន្តតិកម្ម។ គួរកត់សម្គាល់ឃើញថា ការចុះបញ្ជីចំពោះសន្តតិកម្ម មានលក្ខណៈខុសគ្នាពីការចុះបញ្ជីទូទៅ ដោយសារតែការចុះបញ្ជីទូទៅដូចជាការទិញលក់ជាអាទិ៍ តម្រូវឱ្យមានវត្តមានភាគីទាំងពីរដើម្បីធ្វើការចុះបញ្ជីបាន ប៉ុន្តែការចុះបញ្ជីតាមរយៈសន្តតិកម្មតម្រូវឱ្យមានវត្តមានតែភាគីម្ខាងប៉ុណ្ណោះ គឺភាគីសន្តតិជន។ បន្ទាប់ពីមតកជនបានទទួលមរណភាព នៅពេលដែលសន្តតិជនចង់ធ្វើការចុះបញ្ជីលើអចលនទ្រព្យរបស់ខ្លួន ខ្លួនត្រូវតែធ្វើតាមការទាមទារផ្សេងៗរបស់មន្ត្រីចុះបញ្ជី។ ក្នុងការអនុវត្តជាក់ស្តែង ពេលខ្លះមន្ត្រីចុះបញ្ជីទាមទារឱ្យសន្តតិជនមានសេចក្តីសម្រេចពីតុលាការសិន ទើបហ៊ានសម្រេចផ្តល់ការចុះបញ្ជីឱ្យ។ ក្នុងករណីខ្លះមន្ត្រីចុះបញ្ជីតម្រូវឱ្យភាគីដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យតុលាការចេញកំណត់ហេតុអនុវត្ត ឬលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី។ រីឯករណីខ្លះទៀត មន្ត្រីចុះបញ្ជីគ្រាន់តែចង់បានការបញ្ជូនពីតុលាការជាមុនសិន ទើបខ្លួនហ៊ានធ្វើការចុះបញ្ជីឱ្យ។

### ៣.១.២. ផលវិបាកនៃការចុះបញ្ជីអចលនវត្ថុបន្ទាប់ពីទទួលបានដោយសន្តតិកម្ម

នៅពេលដែលប្រជាពលរដ្ឋពុំបានធ្វើការចុះបញ្ជីលើអចលនវត្ថុរបស់ខ្លួន បញ្ហាមួយចំនួនអាចនឹងកើតមានឡើង។ ចំពោះប្រជាពលរដ្ឋដែលមានបំណងលក់អចលនវត្ថុរបស់ខ្លួន ពួកគាត់នឹងពិបាកលក់ ពីព្រោះអ្នកកាន់កាប់អចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី ពុំទាន់ទទួលបានសិទ្ធិកម្មសិទ្ធិស្របច្បាប់ដែលអាចតតាំងជាមួយតតិយជននៅឡើយទេ។ មួយវិញទៀត អចលនវត្ថុដែលពុំធ្លាប់ឆ្លងកាត់ការចុះបញ្ជី ពុំមានឈ្មោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីឡើយ ជាហេតុនាំឱ្យមានការសន្មត់ថា អចលនវត្ថុនោះជារបស់រដ្ឋ។ ដោយឡែកចំពោះការចុះបញ្ជីជាប្រព័ន្ធ ឬដាច់ដោយដុំ មន្ត្រីវាស់វែងដី នឹងចុះទៅត្រួតពិនិត្យក្នុងបញ្ជីសុរិយោដីដើម្បីផ្ទៀងផ្ទាត់ទិន្នន័យ។ មន្ត្រីវាស់

វែងដី ត្រូវធ្វើការត្រួតពិនិត្យព័ត៌មានដីជាប់ព្រំប្រទល់នៃអចលនវត្ថុដែលត្រូវបានស្នើសុំចុះបញ្ជីនោះ។ ហើយប្រសិនបើ ដីជាប់ព្រំប្រទល់នោះបានចុះបញ្ជីរួច មន្ត្រីវាស់វែងនឹងងាយស្រួលកំណត់ព្រំប្រទល់។ ប៉ុន្តែ បើដីជាប់ព្រំប្រទល់នោះ ពុំទាន់បានចុះបញ្ជីដែរ នោះភាគីអាចនឹងមានជម្លោះអំពីព្រំប្រទល់របស់ខ្លួន។ ដូចនេះ ការចុះបញ្ជីដីធ្លីនៅកម្ពុជានៅមានកម្រិតនៅឡើយ ដែលអាចធ្វើឱ្យប្រជាពលរដ្ឋដែលមិនបានធ្វើការចុះបញ្ជីដីធ្លី ប្រឈមនឹងបញ្ហាជាច្រើន ដូចជាការបាត់បង់ដីធ្លីជាដើម ដោយសារតែអាចមានអំពើរំលោភបំពានពីអ្នកដទៃ។

សេចក្តីសម្រេចស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត បានចែងពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ជាសំណង់ ឬ/និង ដី រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត[57]។ មានន័យថា ការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយមូលហេតុសន្តតិកម្ម មិនតម្រូវឱ្យមានការបង់ពន្ធប្រថាប់ត្រាទៀតឡើយ ដែលផ្ទុយនឹងការចុះបញ្ជីផ្សេងៗដូចជា ការទិញលក់ជាអាទិ៍ដែលតម្រូវឱ្យអ្នកស្នើសុំចុះបញ្ជី បង់ពន្ធប្រថាប់ត្រាជាមុនសិន ទើបអាចដំណើរការនីតិវិធីចុះបញ្ជីបាន។ គួរបញ្ជាប់ផងដែរថា ការលើកលែងនេះ មិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួចហើយនោះទេ[58]។ ចំណុចនេះចង់បញ្ជាក់ថាប្រជាពលរដ្ឋដែលបានបង់ពន្ធប្រថាប់ត្រាមុនពេលដែលសេចក្តីសម្រេចនេះចូលជាធរមាន ពុំអាចទាមទារប្រាក់ពន្ធនោះត្រលប់មកវិញឡើយ។

វត្តមាននៃសេចក្តីសម្រេចខាងលើ បានផ្តល់នូវគុណសម្បត្តិមួយចំនួនដល់ប្រជាពលរដ្ឋជាពិសេសវាជាការលើកទឹកចិត្តដល់ប្រជាពលរដ្ឋមួយចំនួនឱ្យងាកមកធ្វើការចុះបញ្ជីវិញ ដែលកន្លងមកខ្លួនពុំធ្លាក់យកចិត្តទុកដាក់លើបញ្ហានេះទាល់តែសោះ។ យ៉ាងណាមិញ ការលើកលែងពន្ធប្រថាប់ត្រានេះ ក៏ផ្តល់នូវបញ្ហាប្រឈមផងដែរ។ កន្លងមក ការបង់ពន្ធប្រថាប់ត្រានៃការចុះបញ្ជីអចលនវត្ថុ ជាប្រភពចំណូលយ៉ាងសំខាន់មួយចូលដល់រដ្ឋ។ ដូចនេះ បន្ទាប់ពីសេចក្តីសម្រេចនេះ

---

[57] សេចក្តីសម្រេចលេខ ០៤ សសរ, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦, ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត, ប្រការ១។

[58] សេចក្តីសម្រេចលេខ ០៤ សសរ, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦, ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត, ប្រការ២។

ចូលជាធរមាន រដ្ឋនឹងបាត់បង់ប្រភពចំណូលដ៏ធំមួយនេះ។ ម៉្យាងវិញទៀត ការលើកលែងពន្ធប្រថាប់ត្រានេះ ក៏បានធ្វើឡើងស្របពេលដែលរដ្ឋមានការតំឡើងប្រាក់បៀវត្សដល់មន្ត្រីរាជការដែលនោះអាចនឹងប៉ះពាល់សេដ្ឋកិច្ចរបស់ប្រទេសជាតិ ដោយសារតែកន្លងមករដ្ឋពឹងផ្អែកមួយផ្នែកនៃការយកពន្ធពីប្រជាពលរដ្ឋដើម្បីផ្តល់ប្រាក់បៀវត្សដល់មន្ត្រីរបស់ខ្លួន។

### ៣.១.៣. អានុភាពនៃកិច្ចសន្យា

ក្នុងចំណោមមតិកទាំងអស់ មានមតិកខ្លះត្រូវការមានទម្រង់កំណត់មួយដើម្បីផ្ទេរសិទ្ធិ ឬដើម្បី ឱ្យមានល័ក្ខខ័ណ្ឌតតាំង។[59] ចំពោះអចលនវត្ថុ ទម្រង់ដែលទាមទារ គឺការចុះបញ្ជីបញ្ជាក់អំពីការផ្ទេរដោយត្រូវធ្វើលិខិតយថាភូត។ នៅពេលដែលបានចុះបញ្ជីក្នុងបញ្ជីអចលនវត្ថុហើយ សិទ្ធិនេះត្រូវបានសន្មតថា ជាសិទ្ធិរបស់អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីនោះ[60]។ ប្រសិនបើសន្តតិជនដែលទទួលបានអចលនវត្ថុ មិនបានចុះបញ្ជីទេ សន្តតិជននោះពុំទាន់មានសិទ្ធិកម្មសិទ្ធិជាសាធារណៈឡើយ។ ដូចនេះ សន្តតិជនទទួលបានអចលនវត្ថុដែលមិនបានចុះបញ្ជី មានបំណងចង់ផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះដោយកិច្ចសន្យាដូចជាកិច្ចសន្យាទិញលក់ជាអាទិ៍ កិច្ចសន្យានោះពុំមានសុពលភាពគ្រប់គ្រាន់ក្នុងការតតាំងជាមួយតតិយជនឡើយ។

### ៣.១.៤. ដំណោះស្រាយ

#### ៣.១.៤.១. ការចុះបញ្ជីអចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី

ប្រសិនបើសន្តតិជនដែលបានទទួលអចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជីពីមុន គួរងាកមកធ្វើការចុះបញ្ជីវិញ។ នៅពេលដែលចុះបញ្ជីរួចរាល់ សន្តតិជននឹងក្លាយជាម្ចាស់សិទ្ធិដែលមានសុវត្ថិភាពក្នុងការទទួលបានកម្មសិទ្ធិរបស់ខ្លួន។

ដោយសារតែអចលនវត្ថុមិនធ្លាប់ឆ្លងកាត់ការចុះបញ្ជី អចលនវត្ថុនោះនៅតែជាកម្មសិទ្ធិរបស់រដ្ឋ[61] ហើយអ្នកកាន់កាប់មុនៗពុំទទួលបានសិទ្ធិកម្មសិទ្ធិនៅឡើយ។ ដូចនេះ សន្តតិជនដែលមានបំណងចុះបញ្ជី ត្រូវបញ្ជាក់អំពីការកាន់កាប់មុនៗ តាមពីរករណី គឺមុនឆ្នាំ២០០១ និង ក្រោយឆ្នាំ២០០១។

ការកាន់កាប់មុនឆ្នាំមុនឆ្នាំ ២០០១ ត្រូវអនុវត្តតាមច្បាប់ភូមិបាលឆ្នាំ ២០០១។ មុនឆ្នាំ ២០០១ អ្នកចូលកាន់កាប់ដីឯកជនរបស់រដ្ឋ ទទួលបានត្រឹមសិទ្ធិភោគៈប៉ុណ្ណោះ។ មាត្រា ៣០ នៃ

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ថ្មី ចំណុចទី២។
[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣៧ ចំណុចទី១។
[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៦១ បញ្ញត្តិថា អចលនវត្ថុដែលគ្មានម្ចាស់ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ។

ច្បាប់ភូមិបាលឆ្នាំ ២០០១ បានបញ្ញត្តថា "បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនឹងមិនមានការជំទាស់ចាប់ពី៥(ប្រាំ) ឆ្នាំ យ៉ាងតិចគិតមកដល់ការបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើ អចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្ម-សិទ្ធិស្ថាពរ។"[62] គោលការណ៍សំខាន់ត្រង់ចំណុចនេះ គឺការចូលកាន់កាប់ដោយសន្តិវិធី។ អ្នកដែលគិតរយៈពេលចាំបាច់នៃការកាន់កាប់អចលនវត្ថុសម្រាប់លទ្ធកម្មកម្មសិទ្ធិពេញលេញ ត្រូវរាប់ចាប់ពីខ្មោចបានចូលកាន់កាប់ទ្រព្យនោះ[63] មានន័យថា រយៈប្រាំឆ្នាំ ជារយៈពេលទាមទារដោយច្បាប់ដើម្បីអាចស្នើ-សុំចុះបញ្ជីបាន ហើយរយៈពេលកាន់កាប់ អាចគិតបញ្ចូលគ្នារវាងអ្នកកាន់កាប់មុន និងក្រោយ។ ដូចនេះទោះបីជាអចលនវត្ថុមិនធ្លាប់ធ្វើការចុះបញ្ជីក៏ដោយ អ្នកស្នើសុំចុះបញ្ជី អាចធ្វើការចុះបញ្ជីបាន ដោយបង្ហាញថាអចលនវត្ថុដែលជាមតិកនោះ ត្រូវបានចូលកាន់កាប់មុនឆ្នាំ២០០១ លើសពីប្រាំឆ្នាំ ហើយការកាន់កាប់ស្របនឹងមាត្រា ៣០។

ការកាន់កាប់ក្រោយឆ្នាំ ២០០១ ត្រូវអនុវត្តតាមច្បាប់ភូមិបាលឆ្នាំ ២០០១ រហូលដល់មានក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលមកនិរាសករច្បាប់ភូមិបាល។ រាល់ការចូល កាន់កាប់អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋទោះបីប្រភេទណាក៏ដោយ ពុំទទួលបានសិទ្ធិចុះបញ្ជីឡើយ។[64] មាត្រា ១៦២ នៃក្រមនេះ បានបញ្ញត្តពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ "ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និងដឹងលឺជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ។ ចំពោះជនដែលបានកាន់កាប់អចលនវត្ថុដោយសន្តិវិធី និងដឹងលឺជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ បើជននោះសុចរិត និងគ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្តើមកាន់កាប់។"[65] ប្រសិនបើ ជនដែលជាអ្នកកាន់កាប់អចលនវត្ថុដោយមិនទាន់ចុះបញ្ជី បានកាន់កាប់គ្រប់រយៈពេលដូចមានចែងក្នុងមាត្រា ១៦២ ហើយមានបំណាងចង់ផ្ទេរអចលនវត្ថុនោះទៅឱ្យសន្តតិជនរបស់ខ្លួន សន្តតិជនរបស់ជននោះអាចធ្វើការចុះបញ្ជីដោយសំអាងលើលទ្ធកម្មនៃកម្មសិទ្ធិដោយអាជ្ញាយុកាល។

[62] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ២០០១, មាត្រា ៣០ កថាខណ្ឌ១។

[63] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ២០០១, មាត្រា ៧២។

[64] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៦២ ចំណុចទី៣។

[65] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៦២ ចំណុចទី ១ &២។

### ៣.១.៤.២. ការយកចិត្តទុកដាក់ពីរដ្ឋ

ការចុះបញ្ជីអចលនវត្ថុឱ្យបានត្រឹមត្រូវ ពិតជាសំខាន់ណាស់ក្នុងការបញ្ចៀសបញ្ហាដែលអាចកើតមានឡើងខាងលើ។ ដូចនេះ រដ្ឋគួរតែស្វែងរកយន្តការបន្ថែម ដើម្បីជម្រុញឱ្យប្រជាពលរដ្ឋទៅចុះបញ្ជីបន្ត ពេលទទួលបានសិទ្ធិលើអចលនវត្ថុដោយសន្តតិកម្ម។ បន្ថែមពីនេះ រដ្ឋគួរតែផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវយន្តការទាំងនោះផងដែរ។ គួរសង្កេតឃើញថា ទោះបីជាមានសេចក្ដីសម្រេចស្ដីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្ដាយបង្កើតនិងកូនបង្កើត រវាងប្ដីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត ក៏នៅតែមានប្រជាពលរដ្ឋមួយចំនួនមិនបានធ្វើការចុះបញ្ជី ដោយសារតែក្នុងចំណោមនោះ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅជនបទ ពុំទាន់បានដឹងអំពីអត្ថន័យនៃសេចក្ដីសម្រេចនេះនៅឡើយ។ ដូចនេះ ការផ្សព្វផ្សាយពិតជាសំខាន់ណាស់សម្រាប់ជាប្រភពចែកចាយដល់ប្រជាពលរដ្ឋទាំងអស់។ ក្រៅពីនេះ រដ្ឋក៏គួរយកចិត្តទុកដាក់បន្ថែមលើការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចុះបញ្ជី និងបញ្ហាប្រឈមនៃការមិនបានចុះបញ្ជីដល់ប្រជាពលរដ្ឋ។ ពេលខ្លះប្រជាពលរដ្ឋពុំមានសញ្ញាណអ្វីសោះទាក់ទងនឹងកាចុះបញ្ជីនេះ រហូតដល់ខ្លួនមានបញ្ហាលើរឿងនេះ ទើបបានយល់ ប៉ុន្តែនេះហាក់បីជាយឺតពេលបាត់ទៅហើយ។ ដូចនេះ ការផ្សព្វផ្សាយពិតជាសំខាន់ណាស់សម្រាប់ជាប្រភពចែកចាយដល់ប្រជាពលរដ្ឋទាំងអស់។

## ៣.២. អចលនវត្ថុបានចុះបញ្ជីរួច

អចលនវត្ថុដែលបានចុះបញ្ជីរួច សម្ដៅលើអចលនវត្ថុដែលមានប័ណ្ណរួចហើយ (ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជាដើម)។ កន្លងមកឃើញថា អចលនវត្ថុដែលម្ចាស់សិទ្ធិមុនបានចុះបញ្ជីរួច តែសន្តតិជនបន្តបន្ទាប់មិនបានយកទៅចុះបញ្ជីបន្ត នូវតែជួបប្រទះនូវបញ្ហាមួយចំនួន។ ករណីខ្លះ ឪពុកបានផ្ទេរអចលនវត្ថុរបស់ខ្លួនឱ្យទៅសន្តតិជន ប៉ុន្តែសន្តតិជននោះពុំបានធ្វើការចុះបញ្ជី។ ក្រោយមកខ្លួនមានបំណងលក់អចលនវត្ថុនោះ ប៉ុន្តែតាមការពិនិត្យមើលក្នុងសៀវភៅចុះបញ្ជី អចលនវត្ថុនោះមិនមែនជាឈ្មោះរបស់ខ្លួននោះក៏កើតជាបញ្ហាម្ដងទៀត។

### ៣.២.១. មូលហេតុ

ដូចគ្នានឹងចំណុច ៣.១.១ ខាងលើដែរ អចលនវត្ថុខ្លះបានចុះបញ្ជីរួច តែសន្តតិជនបន្តបន្ទាប់មិនបានយកទៅចុះបញ្ជីបន្ត ដោយមូលហេតុចំណេះដឹង និងផ្នត់គំនិតរបស់ប្រជាពលរដ្ឋ និងភាពមិនច្បាស់លាស់នៃយន្តការរបស់រដ្ឋ។

### ៣.២.២. បញ្ហាដែលអាចកើតមាន

ដើម្បីឱ្យក្លាយជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុពិតប្រាកដ ម្ចាស់សិទ្ធិត្រូវធ្វើការចុះបញ្ជីនៅឯមន្ទីរសុរិយោដីដែលអចលនវត្ថុនោះតាំងនៅ។ ទោះបីជាម្ចាស់កម្មសិទ្ធិមុនបានចុះបញ្ជីរួចហើយក៏ដោយ ក៏ម្ចាស់សិទ្ធិបន្ទាប់ត្រូវធ្វើការចុះបញ្ជីដូចគ្នាដែរ បើពុំនោះពុំអាចក្លាយជាម្ចាស់កម្មសិទ្ធិស្របតាមច្បាប់ឡើយ ព្រោះនៅក្នុងបញ្ជីសុរិយោដីនៅតែជាឈ្មោះរបស់ម្ចាស់អចលនវត្ថុមុនដដែល។ បញ្ហាដែលកើតមានឡើងនេះ នឹងធ្វើឱ្យប្រព័ន្ធទិន្នន័យអំពីម្ចាស់កម្មសិទ្ធិមានភាពច្របូកច្របល់ ដោយសារតែអ្នកកាន់កាប់មិនមែនជាម្ចាស់កម្មសិទ្ធិដែលមានឈ្មោះក្នុងបញ្ជី។ ភាពមិនច្បាស់លាស់នៃប្រព័ន្ធទិន្នន័យទាំងអស់នេះ នឹងធ្វើឱ្យងាយកើតមានវិវាទរវាងប្រជាពលរដ្ឋ ហើយមន្ត្រីមានសមត្ថកិច្ច ឬតុលាការក៏ពិបាកក្នុងការដោះស្រាយវិវាទផងដែរ។ ជាឧទាហរណ៍ ក បានផ្ទេរអចលនវត្ថុដែលខ្លួនបានចុះបញ្ជីរួច ទៅឱ្យសន្តតិជន ខ ហើយក្រោយមក ខ ក៏ផ្ទេរបន្តទៅឱ្យសន្តតិជនរបស់ខ្លួន គ។ ដោយសារតែ ខ និង គ ពុំបានធ្វើការចុះបញ្ជីលើអចលនវត្ថុនោះ ជាហេតុធ្វើឱ្យអចលនវត្ថុនោះជារបស់ ក ស្របតាមច្បាប់ដដែលទោះបីជាបច្ចុប្បន្នអចលនវត្ថុនោះកាន់កាប់ដោយ គ។ ក្នុងករណីដែល គ ចង់លក់អចលនវត្ថុនោះ គ ប្រហែលជាពិបាកក្នុងការលក់ណាស់ ដោយសារតែអ្នកដែលមានបំណងចង់ទិញ តែងតែទៅស្រាវជ្រាវឈ្មោះនៅមន្ទីរសុរិយោដី ដើម្បីបញ្ជាក់ថាតើដីនោះជារបស់ គ ឬមិនមែន។ បន្ទាប់ពីរកឃើញថា គ មិនមែនជាម្ចាស់សិទ្ធិ អ្នកដែលមានបំណងទិញ នឹងបញ្ឈប់ចិត្តចង់ទិញ។ ទោះបីជាអ្នកដែលមានបំណងចង់ទិញអចលនវត្ថុនោះបានចទិញដោយខ្លួនមិនបានទៅបញ្ជាក់ឈ្មោះម្ចាស់សិទ្ធិនៅមន្ទីរសុរិយោដីក៏ដោយ ក៏ខ្លួនពិបាកនឹងធ្វើការចុះបញ្ជីបាន ដោយសារតែអចលនវត្ថុនោះមិនមែនជារបស់ គ។ មួយវិញទៀត គ ក៏ពិបាកក្នុងការចុះបញ្ជីជាប្រព័ន្ធ ឬចុះបញ្ជីដាច់ដោយដុំណាស់ ដោយសារតែអចលនវត្ថុដែលខ្លួនកំពុងកាន់កាប់ បានបង្ហាញថា ជាឈ្មោះរបស់អ្នកផ្សេងនៅក្នុងបញ្ជីសុរិយោដី។

### ៣.២.៣. ដំណោះស្រាយ

#### ៣.២.៣.១. ការចុះបញ្ជីអចលនវត្ថុ

បញ្ហាដូចដែលបានរៀបរាប់ខាងលើ ប្រាកដជាអាចដោះស្រាយបាន បន្ទាប់ពីសន្តតិជនធ្វើការចុះបញ្ជីលើអចលនវត្ថុដែលទទួលបានដោយមូលហេតុសន្តតិកម្ម។ គួរកត់សម្គាល់ឃើញថាអចលនវត្ថុ

ដែលសន្តតិជនទទួលបាន ជាម្ចាស់សិទ្ធិមុនបានចុះបញ្ជីរួចទៅហើយ។ ករណីនេះ ពុំចោទជាការលំបាកដូចអចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជីនោះទេ ដោយសារអចលវត្ថុនេះមានទិន្នន័យរួចរាល់នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ដូចនេះ សន្តតិជននៃអចលនវត្ថុ អាចចុះបញ្ជីបាន ដោយគ្រាន់តែបង្ហាញពីលំនាំនៃការផ្ទេរសន្តតិកម្មទាំងអស់ ដូចជាម្ចាស់សិទ្ធិបានផ្ទេរអចលនវត្ថុនោះមកឱ្យខ្លួនដោយមូលហេតុសន្តតិកម្ម ឬបានផ្ទេរបន្តបន្ទាប់ ដែលចុងក្រោយទើបមកដល់ខ្លួន។

#### ៣.២.៣.២. ការយកចិត្តទុកដាក់ពីរដ្ឋ

ចំណុចនេះដូចគ្នាទៅនឹងចំណុច ៣.១.៤.២ ខាងលើដែរ គឺរដ្ឋគួរតែស្វែងរកយន្តការបន្ថែមដើម្បីជម្រុញឱ្យប្រជាពលរដ្ឋដែលទទួលបានអចលនវត្ថុដោយមូលហេតុសន្តតិកម្ម ទៅចុះបញ្ជីបន្តជាពិសេស រដ្ឋគួរតែធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការទាំងអស់នោះ។

# សេចក្ដីសន្និដ្ឋាន

សញ្ញាណនៃសន្តតិកម្ម កើតមានឡើងតាំងពីសម័យហ្វូណនមកម្ល៉េះ ប៉ុន្តែទើបតែលេចចេញរូបរាងជាច្បាប់ពេញលេញតាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ដោយសារតែសង្គមមានការវិវត្តពីសម័យកាលមួយ ទៅសម័យកាលមួយ ទើបសន្តតិកម្មមានការវិវត្តដោយមានការចែងលម្អិតជាងមុននៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ អនុឡោមតាម ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សន្តតិកម្មអាចអនុវត្តតាមយន្តការពីរ គឺសន្តតិកម្មតាមមតកសាសន៍ និងសន្តតិកម្មតាមច្បាប់។ សន្តតិកម្មតាមមតកសាសន៍ ជាសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ក្នុងការបែងចែកមតិករបស់ខ្លួនទៅឱ្យសន្តតិជន ឬតតិយជន។ យ៉ាងណាក៏ដោយ សន្តតិជនទាំងអស់ មានសិទ្ធិសម្រេចថា អនុវត្តតាមមតកសាសន៍ ឬមិនអនុវត្តតាម។ ចំណែកឯ សន្តតិកម្មតាមច្បាប់ ជាសន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ក្នុងការបែងចែកទ្រព្យដែលនៅសេសសល់របស់អ្នកស្លាប់ ទៅឱ្យទាយាទ ឬអ្នកស្នងមតិករបស់អ្នកស្លាប់នោះ។ ដោយសារតែ មតកជនពុំបានបន្សល់ទុកមតកសាសន៍ នោះការបែងចែកមតិក ត្រូវធ្វើឡើងដោយផ្អែកទៅលើច្បាប់។ ប្រសិនបើសហសន្តតិជនបានធ្វើការពិភាក្សាបែងចែកមតិក ប៉ុន្តែពុំទទួលបានការព្រមព្រៀង សន្តតិជនណាម្នាក់អាចដាក់ពាក្យប្ដឹងទៅតុលាការ ដោយតុលាការនឹងដោះស្រាយដោយផ្អែកលើច្បាប់។

បន្ទាប់ពីបែងចែកមតិករួចរាល់ ទាំងសន្តតិកម្មតាមមតកសាសន៍ និងសន្តតិកម្មតាមច្បាប់ តម្រូវឱ្យសន្តតិជនដែលទទួលបានអចលនវត្ថុ ធ្វើការចុះបញ្ជីនៅមន្ទីរសុរិយោដីដែលអចលនវត្ថុនោះតាំងនៅ។ ការចុះបញ្ជីអចលនវត្ថុ គឺជាសកម្មភាពនៃការចុះទៅក្នុងសៀវភៅគោលបញ្ជីដីធ្លីដោយអាជ្ញាធរមានសមត្ថកិច្ច នូវស្ថានភាពរូបសាស្ត្រនៃអចលវត្ថុ ជាអាទិ៍ លេខក្បាលដី ទីតាំង ទំហំ និងព្រំប្រទល់ ជាមួយអត្តសញ្ញាណនៃបុគ្គលដែលមានសិទ្ធិនៅលើអចលវត្ថុនោះ។ បន្ទាប់ពីធ្វើការចុះបញ្ជីរួចរាល់ សន្តតិជននៃអចលនវត្ថុនោះ នឹងក្លាយទៅជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុពិតប្រាកដ ដែលទទួលបានលក្ខខណ្ឌតតាំងជាមួយតតិយជន។

តាមការសង្កេត ទោះបីជាការចុះបញ្ជីជារឿងសំខាន់ ប្រជាពលរដ្ឋភាគច្រើននាពេលបច្ចុប្បន្ន ហាក់បីដូចជាពុំទាន់យល់ដឹងច្បាស់អំពីសារៈសំខាន់ និងនីតិវិធីនៃការចុះបញ្ជី ហើយក៏ពុំបានទៅចុះបញ្ជីអចលនវត្ថុឡើយបន្ទាប់ពីទទួលបានមតិក។ សន្តតិជនដែលមិនបានចុះបញ្ជីអាចប្រឈមនឹងការបាត់បង់អចលនវត្ថុ ដោយសារតែអចលនវត្ថុដែលមិនបានចុះបញ្ជីអាចមានងាយនឹងរងអំពើរំលោភបំពានពីអ្នកដទៃ។ ម្យ៉ាងវិញទៀត ចំពោះយន្តការច្បាប់វិញ ក៏ពុំទាន់ចែងឱ្យបានលម្អិតអំពីការចុះបញ្ជីផ្ទេរអចលនវត្ថុនៅឡើយ ដែលនេះបង្ហាញឱ្យឃើញពីភាពខ្វះចន្លោះនៃច្បាប់នៅកម្ពុជា

នោះមន្ត្រីចុះបញ្ជី នឹងមិនអាចក្តោបព័ត៌មាននៃការចុះបញ្ជីបានទេ។ ដោយសារតែមិនមានយន្តការគ្រប់គ្រាន់ ពេលខ្លះការអនុវត្តជាក់ស្តែងធ្វើឡើងដោយយកគំរូតាមលំនាំមុនៗ។ ចំពោះករណីអចលនវត្ថុដែលមិនធ្លាប់បានចុះបញ្ជី អចលនវត្ថុនោះនៅតែពុំទាន់មានម្ចាស់នៅឡើយ ទោះបីជាបច្ចុប្បន្នមានអ្នកកំពុងកាន់កាប់។ រីឯករណី អចលនវត្ថុបានចុះបញ្ជីរួច តែសន្តតិជនបន្តបន្ទាប់មិនបានយកទៅចុះបញ្ជីបន្ត ទោះបីជាម្ចាស់កម្មសិទ្ធិមុនបានចុះបញ្ជីរួចហើយក៏ដោយ ក៏ម្ចាស់សិទ្ធិបន្ទាប់ត្រូវធ្វើការចុះបញ្ជីដូចគ្នាដែរ បើពុំនោះពុំអាចក្លាយជាម្ចាស់កម្មសិទ្ធិស្របតាមច្បាប់ដែលអាចតតាំងជាមួយតតិយជនឡើយ ព្រោះនៅក្នុងបញ្ជីសុរិយោដីនៅតែជាឈ្មោះរបស់ម្ចាស់អចលនវត្ថុមុនដដែល។ ករណីទាំងពីរនេះ ប្រាកដជានាំមកនូវបញ្ហាប្រឈមផ្សេងៗ ដូចជា អាចមានការរំលោភបំពានលើសិទ្ធិប្រត្យក្សពីអ្នកដទៃ ពិបាកក្នុងការផ្ទេរកម្មសិទ្ធិបន្ត និងធ្វើឱ្យព័ត៌មាននៅក្នុងបញ្ជីសុរិយោដីច្របូកច្របល់ជាដើម។ លើសពីនេះ ដើម្បីលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលទទួលបានអចលនវត្ថុដោយមូលហេតុសន្តតិកម្មទៅចុះបញ្ជី រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីសម្រេចស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត។ គួរសង្កេតឃើញថា ក្នុងអំឡុងពេលដ៏ខ្លីនេះ ទោះបីជាមានសេចក្តីសម្រេចនេះក៏ដោយ ក៏កំណើននៃការចុះបញ្ជីលើអចលនវត្ថុដែលទទួលបានពីតាយាយ ឪពុកម្តាយ សាច់ញាតិ ដោយមូលហេតុនៃសន្តតិកម្ម មិនទាន់មានការកើនឡើងដែរ។ ការនិយាយបែបនេះដោយផ្អែកលើមូលហេតុដូចជាការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងភាពខ្វះការយកចិត្តទុកដាក់ ភាពមិនច្បាស់លាស់នៃយន្តការរបស់រដ្ឋ។ ប៉ុន្តែទៅថ្ងៃអនាគត ការចុះបញ្ជីដោយយោងតាមសេចក្តីសម្រេចនេះនឹងកើនឡើង ពីព្រោះអចលនវត្ថុនៅកម្ពុជាបន្តកើនតម្លៃខ្លាំង និងជាប្រចាំ ធ្វើឱ្យអ្នកមានអចលនវត្ថុត្រូវការយន្តការការពារជាជាងយន្តការព្យាបាល និងការសម្លឹងឃើញយន្តការដោះស្រាយវិវាទពាក់ព័ន្ធជម្លោះដីធ្លីមានភាពស្មុគស្មាញ និងខ្វះប្រសិទ្ធភាព។

# អនុសាសន៍

ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការចុះបញ្ជីអចលនវត្ថុដោយមូលហេតុសន្តតិកម្ម ដែលកំពុងតែកើតមានឡើងនាពេលបច្ចុប្បន្ន និងបញ្ហាដែលអាចនឹងកើតមានឡើងនៅពេលអនាគត រាជរដ្ឋាភិបាលគួរតែបង្កើតយន្តការឱ្យបានជាក់លាក់ និងច្បាស់លាស់លើការផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម។ ទន្ទឹមនឹងនេះ រដ្ឋគួរតែយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាល និងអប់រំដល់មន្ត្រីជំនាញ ព្រោះថាទោះបីជាមានយន្តការគ្រប់គ្រាន់ហើយយ៉ាងណា បើមន្ត្រីជំនាញពុំមានសមត្ថភាពក្នុងការយល់ដឹងទេ ក៏ការអនុវត្តពុំអាចប្រព្រឹត្តទៅបានរលូនដូចការគ្រោងទុក ឬអនុលោមត្រឹមត្រូវតាមស្មារតីនៃច្បាប់នោះទេ។ មន្ត្រីជំនាញក៏អាចរួមចំណែកមួយផ្នែកធំក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឱ្យកាន់តែមានការយល់ដឹងអំពីការផ្ទេរកម្មសិទ្ធិដីធ្លីដោយមូលហេតុសន្តតិកម្មនេះផងដែរ។

ការចូលអន្តរាគមពីរដ្ឋ ពុំទាន់គ្រប់គ្រាន់នៅឡើយ ដូច្នេះទាមទារឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីអាចដោះស្រាយបញ្ហាដែលបានកើតមានកន្លងមក។ ហេតុនេះ រដ្ឋត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការទាំងអស់នោះ ជាពិសេសដល់ប្រជាពលរដ្ឋដែលរស់នៅជនបទ ដោយសារតែប្រជាពលរដ្ឋដែលរស់នៅទីនោះ ភាគច្រើនពុំសូវទទួលបានការអប់រំគ្រប់គ្រាន់ដូចប្រជាពលរដ្ឋដែលរស់នៅទីក្រុងឡើយ។ ប្រជាពលរដ្ឋគួរតែចូលរួមស្វែងយល់ឱ្យបានច្បាស់អំពីការវិវត្តនៃច្បាប់ នីតិវិធីនៃការផ្ទេរមតិក និងការចុះបញ្ជីអចលនវត្ថុ។ ស្ថាប័នទទួលបន្ទុកអាចធ្វើការផ្សព្វផ្សាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងខិតប័ណ្ណនានា។ នៅពេលដែលប្រជាពលរដ្ឋមានការយល់ដឹងអំពីសារៈប្រយោជន៍ និងតួនាទីរបស់ខ្លួនកាន់តែទូលំទូលាយពាក់ព័ន្ធនឹងបញ្ហានេះ ប្រជាពលរដ្ឋ នឹងអាចចូលរួមកាន់តែច្រើនក្នុងការទៅចុះបញ្ជីផ្ទេរអចលនវត្ថុដោយមូលហេតុសន្តតិកម្ម ព្រមទាំងកាត់បន្ថយជម្លោះទាក់ទងនឹងករណីនេះផងដែរ។ អាស្រ័យហេតុនេះ ការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ទាំងរដ្ឋាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ និងប្រជាពលរដ្ឋ គឺជាធាតុចាំបាច់ក្នុងការលើកកម្ពស់ការចុះបញ្ជីផ្ទេរសន្តតិកម្មនៅកម្ពុជា ក៏ដូចជាធានាសុវត្ថិភាពគតិយុត្តជូនប្រជាពលរដ្ឋ ក្នុងទិសដៅនាំនាវាកម្ពុជាឆ្ពោះទៅរកវឌ្ឍនភាពជានិច្ច។

# ឯកសារយោង

## I. អត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង, លេខ នស/រកម០៧១០/០១៣, ១០ កក្កដា ២០១០។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ស្តីពីភូមិបាល, លេខ ១០០ក្រ, ១៣ តុលា ១៩៩២។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ១៧ កក្កដា ១៩៨៩។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩២០(១៩៦៧)

ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កឃ.ដនស.ប្រក/១៣, ២៩ មករា ២០១៣។

សេចក្តីសម្រេចស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយបង្កើត និងកូនបង្កើត រវាងប្តីនិងប្រពន្ធ និង រវាងយាយ-តាបង្កើតនិងចៅបង្កើត, លេខ ០៤ សសរ, ១០ មករា ២០១៦។


## II. សៀវភៅ និងឯកសារផ្សេងៗ


ក្រសួងយុត្តិធម៌. *សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគទី៦, គន្ថីទី៨ ទី៩.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០។

ជួន ណាត. *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២.* ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨។

តាកាហាស៊ី តូមូកុ. *នីតិរដ្ឋប្បវេណី ភាគទី៧ ស្ដីពីញាតិ និងសន្តតិកម្ម, បោះពុម្ពលើកពី២.* យ៉ឺហិកាគឹ, ឆ្នាំ២០០៩។

មជ្ឈមណ្ឌលឯកសារកម្ពុជា, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក.* ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៥។

## ឧបសម្ព័ន្ធ

ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយ.ដនស.ប្រក/១៣, ២៩ មករា ២០១៣។

សាលដីការសម្រេចស្តីពីការសុំបញ្ជាក់ទាយាទ និងបែងចែកមត៌ក, លេខ ១៣៦, ២៨ សីហា ២០១២។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ:៣.០៨៧យ.ដ.ន.ស.ប្រក/១៣

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
រាជធានីភ្នំពេញ, ថ្ងៃទី...២៥...ខែ.មករា ឆ្នាំ.២០១៣

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
- តាមការចាំបាច់ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីអចលនវត្ថុឲ្យបានត្រឹមត្រូវទៅតាមក្រមរដ្ឋប្បវេណី។

**ប្រការ ២ : គោលបំណង**

ប្រកាសនេះ មានគោលបំណងបញ្ញត្តនូវនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជី និងនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដោយយោងតាមក្រមរដ្ឋប្បវេណី។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ ត្រូវយកមកអនុវត្តចំពោះដី ដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ហើយក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ។

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើការចុះបញ្ជីដូចខាងក្រោម ៖

ក– ការផ្ទេរ ការផ្លាស់ប្តូរ ការកែតម្រូវ ការរំលត់កម្មសិទ្ធិ

ខ– ការបង្កើត ការផ្ទេរ ការផ្លាស់ប្តូរ ការកែតម្រូវ ការរំលត់សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក

គ– ការបង្កើត ការផ្លាស់ប្តូរ ការកែតម្រូវ និងការរំលត់សេវភាព

**ប្រការ ៤ : និយមន័យ**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

១– បុគ្គល គឺសំដៅទៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គល ។

២– ចំណុចដែលត្រូវចុះបញ្ជី គឺសំដៅទៅលើចំណុចដែលត្រូវចុះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះ ។

៣– បុគ្គលមានសិទ្ធិចុះបញ្ជី គឺសំដៅទៅលើបុគ្គល ដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី ។

៤– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី គឺសំដៅទៅលើបុគ្គលដែលទទួលនូវការប៉ះពាល់ផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជី ។

៥– បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺសំដៅទៅលើបុគ្គលមានសិទ្ធិចុះបញ្ជី ឬ បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ឬ បុគ្គលផ្សេងទៀតដែលត្រូវប្រើសិទ្ធិចុះបញ្ជី ឬ ត្រូវអនុវត្តកាតព្វកិច្ចចុះបញ្ជី ។

៦– បុគ្គលទទួលបន្តជាសកល គឺសំដៅទៅលើបុគ្គលដែលទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ចទាំងអស់ ដែលបុគ្គលនោះមានតាមរយៈសន្តតិកម្ម ឬ ការរួមបញ្ចូលនៃនីតិបុគ្គល ។

៧– ការចុះបញ្ជី អំពីការផ្លាស់ប្តូរ គឺសំដៅទៅលើការចុះបញ្ជី ដែលត្រូវធ្វើឡើង ក្នុងករណីដែលមានការផ្លាស់ប្តូរចំណុចណាមួយ ដែលបានចុះបញ្ជីរួចហើយ ដើម្បីផ្លាស់ប្តូរនូវចំណុចនោះ។

- សោហ៊ុយក្នុងការធ្វើកិច្ចសន្យា
- អំឡុងពេលនៃការលោះ

ប្រការ ២៣ : ចំណុចដែលត្រូវចុះបញ្ជី អំពីការផ្ទេរសិទ្ធិប្រាតិភោគប្រត្យក្ស តាមការធ្វើអនុប្បទានមួយភាគ ជាអាទិ៍ នៃសិទ្ធិលើបំណុល ដែលត្រូវបានធានា

ករណីធ្វើអនុប្បទានមួយភាគ ឬ ឧបាទេសកម្មដោយការសងមួយភាគ នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ក្រៅពីចំណុចដូចមានចែងក្នុងប្រការ ១៤ ខាងលើ ចំណុចដែលត្រូវចុះបញ្ជី អំពីការផ្ទេរមួយភាគនៃឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក គឺចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល ដែលធ្វើអនុប្បទាន ឬ ឧបាទេសកម្មដោយការសងនោះ ។

ប្រការ ២៤ : ចំណុចដែលត្រូវចុះបញ្ជី អំពីការចាត់ចែងសិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក

បញ្ញត្តិប្រការ ១៩ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត ឬ ការធ្វើអនុប្បទាន ឬ ការបោះបង់សិទ្ធិលើការបញ្ចាំ ។

បញ្ញត្តិប្រការ ២០ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត ឬ អនុប្បទាន ឬ ការបោះបង់ហ៊ីប៉ូតែក ។

ប្រការ ២៥ : ចំណុចដែលត្រូវចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម

ក្រៅពីចំណុចដូចមានចែងក្នុងប្រការ ២០ ចំណុចដែលត្រូវចុះបញ្ជី អំពីឧបាទេសកម្ម ដោយផ្អែកលើមាត្រា ៨៥៨ នៃក្រមរដ្ឋប្បវេណី ត្រូវមានដូចខាងក្រោម ៖

- អត្តសញ្ញាណអចលនវត្ថុដែលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់លើគេទទួលបានពីការសង
- ថ្លៃលក់អចលនវត្ថុ
- ចំនួនប្រាក់សងដែលម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់លើគេទទួលបាន
- អត្តសញ្ញាណសិទ្ធិលើបំណុលដែលត្រូវបានធានាដោយប្រាតិភោគ

# ជំពូកទី ៤
# ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ
## ផ្នែកទី ១
## ទម្រង់ និងឯកសារភ្ជាប់ពាក្យសុំចុះបញ្ជី

ប្រការ ២៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី *

ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវសរសេរនូវចំណុចដូចខាងក្រោម និងទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ ៖

- ឈ្មោះប្រទេសជាផ្លូវការ
- បាវចនា
- រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ
- គោលបំណងនៃពាក្យសុំចុះបញ្ជី

- មូលហេតុនៃពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ នៅពេលសាមីខ្លួនមិនមែនជាបុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះរបស់អភិបាលតំណាងនីតិបុគ្គល នៅពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជានីតិបុគ្គល
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ក្នុងករណីការដាក់ពាក្យសុំចុះបញ្ជីត្រូវបានធ្វើឡើងដោយអ្នកតំណាង
- អត្តសញ្ញាណ នៃអចលនវត្ថុ
- កិច្ចសន្យាហាមមិនឲ្យបែងចែកអចលនវត្ថុអវិភាគ ជាអាទិ៍ ប្រសិនបើមាន
- មូលហេតុ ដែលនាំឲ្យមានឧបាទេសកម្ម និងកាលបរិច្ឆេទនៃមូលហេតុនោះ នៅពេលដែលអ្នកដាក់ពាក្យសុំ គឺជាឧបាទេសិក
- ឈ្មោះ និងអាសយដ្ឋានរបស់ឧបាទេសិក ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក
- ឈ្មោះរបស់មតកជន ឬ របស់នីតិបុគ្គលដែលត្រូវបានរួមបញ្ចូល នៅពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជាបុគ្គលទទួលបន្តជាសកល
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ ហត្ថលេខា ឬ ស្នាមម្រាមដៃរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី
- ចំណែករបស់ម្ចាស់សិទ្ធិម្នាក់ៗ ក្នុងករណីដែលមានម្ចាស់សិទ្ធិពីរ ឬ ច្រើននាក់
- ឯកសារភ្ជាប់

**ប្រការ ២៧ : បទប្បញ្ញត្តិទូទៅចំពោះឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី**

នៅពេលដាក់ពាក្យសុំចុះបញ្ជី បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនដូចខាងក្រោម ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ ៖

- ឯកសារដែលបញ្ជាក់ អំពីអត្តសញ្ញាណរបស់បុគ្គល ដែលដាក់ពាក្យសុំចុះបញ្ជី
- លិខិតបញ្ជាក់សិទ្ធិតំណាងរបស់អភិបាលតំណាងនីតិបុគ្គល ប្រសិនបើអ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល
- ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីនោះ ជាជនដែលស្ថិតនៅក្រោមអ្នកតំណាង ដែលកំណត់ដោយច្បាប់
- លិខិតប្រគល់សិទ្ធិតំណាង ក្នុងករណីដែលពាក្យសុំធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ
- ឯកសារបញ្ជាក់អំពីមូលហេតុ នៃការចុះបញ្ជី
- ឯកសារបញ្ជាក់អំពីមូលហេតុ នៃឧបាទេសកម្ម ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក
- សាលក្រម ឬ សាលដីកាស្ថាពរ ជាអាទិ៍ ក្នុងករណីដែលពាក្យសុំចុះបញ្ជី ត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ ជាអាទិ៍
- ឯកសារបញ្ជាក់ពីការយល់ព្រមរបស់តតិយជន ក្នុងករណីពាក់ព័ន្ធផលប្រយោជន៍តតិយជននោះ
- ឯកសារបញ្ជាក់អំពីសន្តតិកម្ម ឬ ការរួមបញ្ចូលគ្នានៃនីតិបុគ្គល ក្នុងករណីពាក្យសុំចុះបញ្ជី ដែលមានចែងក្នុងកថាខណ្ឌទី ២ ប្រការ ១០ និង ប្រការ ១១ នៃប្រកាសនេះ
- គំនូសបង្ហាញសេរភាព
- គំនូសបង្ហាញទីតាំងអាគារ ដែលជាកម្មវត្ថុនៃផលុបភោគ

- ប័ណ្ណ
- ឯកសារពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ផ្នែកទី ២
## ពាក្យសុំចុះបញ្ជី អំពីកម្មសិទ្ធិ

**ប្រការ ២៨ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ**

នៅពេលកម្មសិទ្ធិ ត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖
- ការផ្ទេរកម្មសិទ្ធិទាំងមូល
- ការផ្ទេរកម្មសិទ្ធិមួយផ្នែក

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖
- ការលក់ទិញ
- ប្រទានកម្ម
- ការដូរ
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។

គ– បុគ្គលមានសិទ្ធិចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី
- ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មី

ង– អត្តសញ្ញាណ នៃអចលនវត្ថុ
- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

**ប្រការ ២៩ : ពាក្យសុំចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ**

នៅពេលចំណែកកម្មសិទ្ធិអវិភាគ ត្រូវបានផ្ទេរទាំងមូល ឬ មួយផ្នែក ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណងណាមួយដូចខាងក្រោម ៖

- ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគទាំងមូលរបស់ម្ចាស់កម្មសិទ្ធិអវិភាគ ឈ្មោះ.........នៃលេខ...... ឬ
- ការផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយផ្នែករបស់ម្ចាស់កម្មសិទ្ធិអវិភាគ ឈ្មោះ.........នៃលេខ......

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលក់ទិញ
- ប្រទានកម្ម
- ការដូរ
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬ សាលដីកាស្ថាពរ
- ការបែងចែកកម្មសិទ្ធិអវិភាគ
- ការបោះបង់ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគ ឬ
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ- ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មី

ង- អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៣០ : ពាក្យសុំចុះបញ្ជី អំពីការកែតម្រូវកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ

នៅពេលកម្មសិទ្ធិ ឬ ចំណែកកម្មសិទ្ធិអវិភាគ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថា មានកំហុស ឬ ខកខានមិនបានចុះបញ្ជី ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការកែតម្រូវកម្មសិទ្ធិ ឬ
- ការកែតម្រូវចំណែកកម្មសិទ្ធិអវិភាគ

ខ– មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- មានកំហុស ឬ
- ការខកខានមិនបានចុះបញ្ជី

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

– បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ– ចំណុចដែលត្រូវកែតម្រូវណាមួយដូចខាងក្រោម ៖

- គោលបំណង
- ចំណែក
- ឈ្មោះម្ចាស់កម្មសិទ្ធិ ឬ កម្មសិទ្ធិអវិភាគ

ង– អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ប្រការ ៣១ : ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ

នៅពេលការផ្ទេរកម្មសិទ្ធិត្រូវបានចុះបញ្ជីរួចហើយ ប្រសិនបើមានតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍នៅក្នុងការចុះបញ្ជី ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជីនេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីតតិយជននោះ ។

ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

ក– គោលបំណងណាមួយដូចខាងក្រោម ៖

- ការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិ

- ការលុបការចុះបញ្ជី អំពីការផ្ទេរកម្មសិទ្ធិមួយផ្នែក
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគទាំងមូល
- ការលុបការចុះបញ្ជី អំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយផ្នែក

ខ- មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោម ៖

- ការលុបចោលកិច្ចសន្យា
- ការរំលាយកិច្ចសន្យា
- ការព្រមព្រៀងគ្នារំលាយកិច្ចសន្យា
- មូលហេតុផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

- ឈ្មោះ
- ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្តាយ

ឃ- អត្តសញ្ញាណ នៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬ លេខប័ណ្ណ

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

## ផ្នែកទី ៣
## ពាក្យសុំចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍

### ប្រការ ៣២ : ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

នៅពេលបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ពាក្យសុំចុះបញ្ជីនៅក្នុងប្រការ ២៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរនូវចំណុចដូចខាងក្រោម ៖

ក- គោលបំណង

- ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

ខ- មូលហេតុ និងកាលបរិច្ឆេទ

- ការបង្កើត

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងរដ្ឋប្បវេណីលេខ: ១៣៦
ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២
ដីកាសម្រេចលេខ:.............តរ/១៣

# ដីកាសម្រេច
## (សញ្ញាណនៃរឿងក្តី: សុំបញ្ជាក់ទាយាទ និងបែងចែកមរតក)

បានធ្វើនីតិវិធីនៃសេចក្តីបញ្ជាក់ដំបូងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២
ដែលសមាសភាព:
លោក ម៉ុង មុនីនចរិយា ជាចៅក្រម
លោក ទៀង សំណាង ជាក្រឡាបញ្ជី

អ្នកដាក់ពាក្យសុំ:

- ឈ្មោះ ភេទស្រី អាយុ៦៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅក្រុមទី១ ភូមិព្រៃប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

ខ្លឹមសារនៃសេចក្តីសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ:

**១.សុំទទួលស្គាល់:**

-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០៧/០៤/១៩៩៨

-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី១០/០៦/១៩៧០

-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី១០/០២/១៩៧៥

-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០៦/០៣/១៩៧៩

-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០១/០៦/១៩៨១

-ឈ្មោះ ភេទប្រុស កើតនៅថ្ងៃទី០២/១០/១៩៨៥

-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០៩/០៧/១៩៨៧

ជាទាយាទរបស់សពឈ្មោះ ដើម្បីមានសិទ្ធិទទួលមរតក ។

**២.** បែងចែកមរតក នូវដីមួយកន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១/១២/២០០៥ មានទំហំ១៤២៤ម២ ស្ថិតនៅភូមិព្រែកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឲ្យទៅឈ្មោះ ដែលត្រូវជាភរិយានៃសព។

១. <u>អង្គហេតុចាំបាច់ដែលជាមូលហេតុនៃការទាមទារ</u>

បុគ្គលឈ្មោះ ដែលត្រូវជាប្តីរបស់អ្នកដាក់ពាក្យសុំឈ្មោះ និងត្រូវជាឪពុករបស់អ្នកដាក់ពាក្យសុំដទៃទៀត បានទទួលមរណៈភាពនៅក្នុងឆ្នាំ១៩៩៣ និងបានបន្សល់ទុកនូវទ្រព្យជាមរតកជាដីមួយកន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១/១២/២០០៥ មានទំហំ ១៤២៤ម² ស្ថិតនៅភូមិព្រែកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

## ២. សំអាងហេតុ

ក.ការចាប់ផ្តើមសន្តតិកម្ម:

២-១. តាមលិខិតបញ្ជាក់របស់មេឃុំទឹកថ្លាលេខ ១៣៦/២០១២ ល.ប ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ [1] ក៏ដូចជាតាមការទទួលស្គាល់របស់ភាគីអ្នកដាក់ពាក្យសុំដែរ [2] ឃើញថា ឈ្មោះ ពិតជាបានទទួលទទួលមរណៈភាព នៅក្នុងឆ្នាំ ១៩៩៣ ប្រាកដមែន ហើយសព លោក ពិតជាបានបន្សល់ទុកនូវដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១/១២/២០០៥ មានទំហំ ១.៤២៤ម² ស្ថិតនៅភូមិព្រែកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលជាទ្រព្យរួមប្តីប្រពន្ធ ជាមួយនឹងឈ្មោះ [3]។

២-២. មុនពេលមរណៈភាពឈ្មោះ មិនបានធ្វើមតកសាសន៍តាមទម្រង់ណាមួយទុកសម្រាប់ការបែងចែកមរតករបស់ខ្លួននោះទេ ដូច្នេះសន្តតិកម្មរបស់សពលោក គឺជាសន្តតិកម្មតាមច្បាប់ ដូចមានបញ្ញត្តិក្នុងមាត្រា ១១៤៥-២ នៃក្រមរដ្ឋប្បវេណី [4] ។

ខ.សន្តតិជន:

**២.៣.** យោងតាមសៀវភៅគ្រួសារចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ របស់ស្នងការនគរបាលខេត្ត ព្រះសីហនុ

---

[1] . (ឯកសារលេខ ៨) លិខិតបញ្ជាក់របស់មេឃុំទឹកថ្លា ស្រុកព្រៃនប់ ។

2 . (ឯកសារលេខ ១៤) កំណត់នៃនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១២ ។

3. (ឯកសារលេខ ១១) វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១/១២/២០០៥

[4] ក្រមរដ្ឋប្បវេណី

មាត្រា. ១១៤៥

១. ...

*២. សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាម បញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។*

និងសេចក្ដីចម្លងបញ្ជាក់កំណើតលេខ ៦៦១/១២ អត្រដ, លេខ ៦៧៥/១២ អត្រដ, លេខ ៦៦២/១២ អត្រដ, លេខ ៦៦៤/១២ អត្រដ និងលេខ ៦៦៥/១២ អត្រដ [5] បញ្ជាក់ឱ្យឃើញថា សពលោក

ពិតជាប្ដីប្រពន្ធនឹងគ្នាប្រាកដមែន ហើយអ្នកទាំង ពីរមានកូនចំនួន០៦នាក់ ដែលក្នុងនោះរួមមាន ១.ឈ្មោះ ភេទប្រុស កើតថ្ងៃទី ១០/០២/១៩៧០ , ២. ឈ្មោះ ភេទប្រុស កើតថ្ងៃទី ១០/០២/១៩៧៥ , ៣.ឈ្មោះ ភេទស្រី កើតថ្ងៃទី០៦/០៣/១៩៧៩ , ៤.ឈ្មោះ ភេទស្រី កើតថ្ងៃទី០១/០៦/១៩៨១ , ៥.ឈ្មោះ ភេទប្រុស កើតថ្ងៃទី០២/១០/១៩៨៥ និង ៦.ឈ្មោះ ភេទប្រុស កើតថ្ងៃទី០៩/០៧/១៩៨៧ ។

**២.៤.** ដោយហេតុថា អ្នកដាក់ពាក្យសុំឈ្មោះ គឺជាសហព័ទ្ធរបស់សពឈ្មោះ ហើយឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ គឺជាកូនបង្កើតរបស់សពឈ្មោះ ដែរ ហើយអ្នកទាំងប្រាំពីរនាក់នេះនៅមានជីវិតរស់នៅនៅឡើយ និងមិនមានភស្តុតាងណាដែលសឱ្យឃើញថា អ្នកទាំងនេះជាអភ័ព្វបុគ្គលនោះទេ ដូច្នេះតាមមាត្រា ១១៤៩-១, ១១៥៦-១ និង ១១៦១ នៃក្រមរដ្ឋប្បវេណី បុគ្គលទាំង ៧ រូបខាងដើមនេះ គឺពិតជាសន្តតិជនរបស់មតកជនឈ្មោះ ប្រាកដមែន ។

**២.៥.** តាមពាក្យសុំចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១២ លោកស្រី បានសុំឱ្យតុលាការទទួលស្គាល់បុគ្គលចំនួន ៧ រូបដូចខាងលើ ជាសន្តតិជន(ទាយាទ)នៃមតកជនឈ្មោះ ប៉ុន្តែជាក់ស្ដែកនៅក្នុងពាក្យសុំមានតែអ្នកស្រី ម្នាក់គត់ ដែលបានផ្ដិត មេដៃស្នើសុំ [6] ម្យ៉ាងទៀតនៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួនបុគ្គលឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ ក៏មិនបានប្ដឹងសុំឱ្យទទួលស្គាល់ពួកខ្លួនជាសន្តតិជនដែរ [7] ហើយថែមទាំងបានថ្លែងការណ៍បោះបង់សន្តតិកម្មរបស់ខ្លួនទៀតផង ។ ដែលយោងតាមមាត្រា ១១៥៦-១[8] និងមាត្រា ១១៦១-១ [9] នៃក្រមរដ្ឋប្បវេណី អ្នកទាំងពីរពិតជាមានគុណភាពជាសន្តតិជនដែលមាន

---

[5] ឯកសារលេខ ៦/១ និង ៦/២ សៀវភៅគ្រួសារចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ របស់ស្នងការនគរបាលខេត្ត ព្រះសីហនុ និងសេចក្ដីចម្លងបញ្ជាក់កំណើតលេខ ៦៦១/១២ អត្រដ, លេខ ៦៧៥/១២ អត្រដ, លេខ ៦៦២/១២ អត្រដ, លេខ ៦៦៤/១២ អត្រដ និងលេខ ៦៦៥/១២ អត្រដ ។

[6] ពាក្យសុំចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១២ ។

[7] ឯកសារ ១៤/៤. កំណត់ហេតុស្ដីពីនិតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទំព័រ ២ និង ៣ ។

[8] ក្រមរដ្ឋប្បវេណី:

មាត្រា ១១៥៦.

១. សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២. ...

[9] ក្រមរដ្ឋប្បវេណី:

មាត្រា ១១៥៦.

សិទ្ធទទួលបាននូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតក្រោមទ្រព្យសម្បត្តិរបស់មតកជន ឈ្មោះ ប្រាកដមែន ។

**២.៦.** យោងតាមសំអាងហេតុខាងលើ សឲ្យឃើញថា តុលាការអាចទទួលស្គាល់តែអ្នកស្រី ម្នាក់គត់ជាសន្តិជនដែលត្រូវទទួលបាននូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតក្រោមទ្រព្យសម្បត្តិរបស់មតកជនឈ្មោះ ។

គ. ទំហំនៃមរតក និងចំណែកដែលកំណត់ដោយច្បាប់:

**២.៧** តាមការអះអាងរបស់អ្នកអ្នកស្រី ក៏ដូចជាកូនទាំងប្រាំមួយនាក់របស់មតក ជនឈ្មោះ ដែរ[10] ជាពិសេសវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១ ២០១-០២១១ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ បញ្ជាក់ឲ្យឃើញថា មតកជនឈ្មោះ ពិតជាបានបន្សល់ទុកនូវទ្រព្យរបស់ខ្លួន ជាដីដែលជាចំណែកក្នុងដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ មាន ទំហំ ១.៤២៤ម$^{២}$ ស្ថិតនៅភូមិព្រែកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

**២.៨** ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ គឺជាទ្រព្យរួមប្តីប្រពន្ធរបស់ឈ្មោះ និង ឈ្មោះ ដូច្នេះ មានន័យថា ទ្រព្យដែលជាមរតកសម្រាប់កម្មវត្ថុនៃការបែងចែក គឺមាទំហំតែភាគពាក់កណ្តាលនៃដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ នេះប៉ុណ្ណោះ រីឯទំហំពាក់កណ្តាលទៀត គឺជាចំណែកដែលស្ថិតក្រោមសិទ្ធិគ្រប់គ្រងរបស់ អ្នកស្រី ក្នុងនាមជាសហព័ទ្ធ ។

**២.៩** ដោយហេតុថា មានតែអ្នកស្រី ម្នាក់គត់ជាសន្តតិជនរបស់ឈ្មោះ រីឯសន្តតិជនដ៏ទៃទៀតដែលជាកូនៗ បានបោះបង់សន្តតិកម្មរបស់ខ្លួនអស់ហើយ ដូច្នេះទំហំពាក់កណ្តាលនៃដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ ដែលជាទ្រព្យរបស់មតកជនឈ្មោះ នោះ ត្រូវបានទៅអ្នកស្រី តែម្នាក់ ។

## ៣.បន្ទុកនៃប្រាក់ប្រដាប់ក្តី:

ចំពោះប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ២២-៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ។

---

១. កូនរបស់មតកជន ត្រូវក្លាយជាសន្តតិកម្មមានលំដាប់ទី ១ ។

២. ...

[10] កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២

## ៤.សេចក្តីសម្រេចបញ្ចប់

**៤.១.** ទទួលស្គាល់ការទាមទាររបស់ភាគីអ្នកដាក់ពាក្យសុំ តាមពាក្យសុំចុះថ្ងៃទី២១ ខែ សីហា ឆ្នាំ២០១២ ដោយ:

**ក. បញ្ជាក់ថា:**

-ឈ្មោះ ភេទស្រី កើតនៅថ្ងៃទី០៧/០៤/១៩៤៨ ជាសន្តតិជនដែលមានសិទ្ធិទទួលបាននូវមរតកដែលជាទ្រព្យ និងកាតព្វកិច្ចរបស់ ។

**ខ.** បែងចែកជាដីមួយកន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៨០២១២០១-០២១១ ចុះថ្ងៃទី០១/១២/២០០៥ មានទំហំ ១៤២៤ម$^{2}$ ស្ថិតនៅភូមិព្រែកប្រស់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ទៅអោយឈ្មោះ ទទួលសិទ្ធបន្តជាម្ចាស់កម្ម សិទ្ធពីខ្មោចឈ្មោះ ។

**៤.២.** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ ។

ដីកាសម្រេចនេះធ្វើនៅថ្ងៃទី.........ខែ..........ឆ្នាំ២០១៣ ។

**ចៅក្រមទទួលបន្ទុក**